**នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស

ភាគីដាក់ឯកសារ៖ មេធាវីការពារក្តីរបស់ មាស មុត

ដាក់ជូន៖ សហចៅក្រមស៊ើបអង្កេត

ភាសាដើម៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ២០១៦

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 01-Aug-2016, 13:56
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ៖ **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**ចម្លើយរួមរបស់ មាស មុត តបនឹងសារណារបស់ *អ្នកដែលមិនមែនជាភាគី* លើបញ្ហាដែលថា តើតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅឆ្នាំ ១៩៧៥-១៩៧៩ ការវាយប្រហារដោយរដ្ឋ ឬ អង្គការនៅលើកងកម្លាំងប្រដាប់អាវុធរបស់ខ្លួន អាចជាការវាយប្រហារដែលសំដៅលើប្រជាជនស៊ីវិលតាមគោលបំណងនៃមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ឬយ៉ាងណា**

---

**ដាក់ដោយ៖**

**សហមេធាវី៖**

អាង ឧត្តម

Michael G. KARNAVAS

**ផ្ញើជូន៖**

**សហចៅក្រមស៊ើបអង្កេត៖**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Michael BOHLANDER

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**ភាគីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

ក្រុមមេធាវីការពារក្តី ០០៤

លោក មាស មុត តាមរយៈសហមេធាវីរបស់គាត់ ដាក់ចម្លើយរួមនេះ[1]។ មានតែទឡ្ហីករណ៍ដែលពាក់ព័ន្ធប៉ុណ្ណោះដែលត្រូវបានពោលប្រាស្រ័យ[2]។ មេធាវីការពារក្តីមិនជំទាស់ឡើយថា ក្នុងជម្លោះប្រដាប់អាវុធ ទាហានរបស់រដ្ឋអាចជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប៉ុន្តែមិនអាចជាកម្មវត្ថុតែមួយគត់នៃឧក្រិដ្ឋកម្មបែបនេះ ដោយមិនមានការវាយប្រហារទូលំទូលាយជាងនេះទៅលើប្រជាជនស៊ីវិល[3]។

## I. ចម្លើយ

### ក. ការកែប្រែបែបប្រតិសកម្មទៅលើនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដើម្បីឆ្លើយតបនឹងគោលនយោបាយ ឬ ក្តីកង្វល់ខាងសីលធម៌ គឺរំលោភលើគោលការណ៍នីត្យានុកូលភាព

#### ១. គ្មានទម្លាប់អនុវត្តន៍របស់រដ្ឋ ឬ *ទស្សនៈច្បាប់* (opinio juris) ចង្អុលបង្ហាញថានិយមន័យតាមទំនៀមទម្លាប់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅឆ្នាំ ១៩៧៥-១៩៧៩ បានអនុញ្ញាតឲ្យទាហានក្លាយជា "ប្រជាជនស៊ីវិល" ឡើយ

១. *អ្នកដែលមិនមែនជាភាគី* អះអាងថា គ្មានការរំលោភបំពានគោលការណ៍នីត្យានុកូលភាពឡើយ ប្រសិនបើនិយមន័យនៃពាក្យ "ប្រជាជនស៊ីវិល" ត្រូវបានពង្រីក ដោយសារមូលហេតុគោលនយោបាយ ឬ សីលធម៌ ដើម្បីដាក់បញ្ចូលទាហានដែលជាគោលដៅរបស់រដ្ឋខ្លួននោះ[4]។ មិនត្រឹម

---

[1] សេចក្តីអំពាវនាវសុំឲ្យដាក់សារណាពីភាគីនៅក្នុងសំណុំរឿង ០០៣ និង ០០៤ និង អ្នកដែលមិនមែនជាភាគី ចុះថ្ងៃទី ១៩ ខែមេសា ឆ្នាំ ២០១៦ ឯកសារ D191 ("សេចក្តីអំពាវនាវសុំឲ្យដាក់សារណា")។

[2] ទឡ្ហីករណ៍លើអង្គហេតុដែលមិនត្រឹមត្រូវ និង គ្មានមូលដ្ឋាន គឺមិនយកជាបានការឡើយ។ *សូមមើល* សារណាដាក់ដោយមជ្ឈមណ្ឌលច្បាប់អន្តរជាតិ និង ប្រៀបធៀប មហាវិទ្យាល័យនីតិសាស្ត្រនៃសកលវិទ្យាល័យ Baltimore ចុះថ្ងៃទី ១៨ ខែឧសភា ឆ្នាំ ២០១៦ ឯកសារ D191/12 ("Baltimore ឯកសារ D191/12") កថាខណ្ឌ ១, ៣, ៧-៩, ១៨, ២០, ២៣។ ទឡ្ហីករណ៍លើអង្គហេតុគឺមិនពាក់ព័ន្ធ។ ភាគី និង *អ្នកដែលមិនមែនជាភាគី* មិនត្រូវបានសុំឲ្យពោលប្រាស្រ័យពីបញ្ហាអង្គហេតុឡើយ។ សេចក្តីអំពាវនាវសុំឲ្យដាក់សារណា កថាខណ្ឌ ៩។ *សូមមើល* ឧបសម្ព័ន្ធ ក ដែលជាបញ្ជីរៀបរាប់អំពីទឡ្ហីករណ៍របស់ *អ្នកដែលមិនមែនជាភាគី*។

[3] Drummond, Webb & Akande ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០១៦ ឯកសារ D191/4 ("Drummond និង អ្នកផ្សេងទៀត ឯកសារ D191/4") កថាខណ្ឌ ១(ក)(i) កថាខណ្ឌ ៧-១០។ Nicholson ចុះថ្ងៃទី ១៣ ខែឧសភា ឆ្នាំ ២០១៦ ឯកសារ D191/8 ("Nicholson ឯកសារ D191/8") ទំព័រ ២។

[4] Saul ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០១៦ ឯកសារ D191/3 ("Saul ឯកសារ D191/3") កថាខណ្ឌ ២០ កថាខណ្ឌ ២២។ Ido Rosenzweig ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០១៦ ឯកសារ D191/7 ("Rosenzweig ឯកសារ D191/7") ទំព័រ ៤ កថាខណ្ឌ ៣ ទំព័រ ៥ កថាខណ្ឌ ២ ទំព័រ ៦ កថាខណ្ឌ ៤។ Williams និង Grey ចុះថ្ងៃទី ១៩ ខែមេសា [sic] ឆ្នាំ ២០១៦ ឯកសារ D191/11 ("William & Grey ឯកសារ D191/11") កថាខណ្ឌ ២១-២២។ Baltimore ឯកសារ D191/12 កថាខណ្ឌ ៨។ មជ្ឈមណ្ឌល

ត្រូវ។ ក្ដីកង្វល់ខាងគោលនយោបាយ និង សីលធម៌[5] អំពីទាហានដែលមិនទទួលបានការការពារ មិនអាចពង្រីកវិសាលភាពច្បាប់ទំនៀមទម្លាប់អន្តរជាតិជាធរមាន ដោយធ្វើឲ្យខាតបង់ដល់គោលការណ៍នីត្យានុកូលភាពបានឡើយ[6] ជាពិសេសក្នុងករណីដែលធាតុផ្សំបរិបទគឺជាបញ្ហាចោទនោះ[7]។

---

សិទ្ធិមនុស្សនៃសាកលវិទ្យាល័យ Queen's University Belfast ចុះថ្ងៃទី ១២ ខែឧសភា ឆ្នាំ ២០១៦ ឯកសារ D191/13 ("QUB ឯកសារ D191/13") កថាខណ្ឌ ១៨។

[5] Baltimore ឯកសារ D191/12 កថាខណ្ឌ ៨ ដែលកត់សម្គាល់យ៉ាងត្រឹមត្រូវថា ទាហានខុសពីជនស៊ីវិល "នៅក្នុងគ្រប់ការពិចារណានៃច្បាប់អន្តរជាតិ" មិនបានដកស្រង់ឯកសារសំអាងណាមួយគាំទ្រអំណះអំណាងរបស់ខ្លួនដែលថា ក្ដីកង្វល់នៃគោលនយោបាយទាក់ទងនឹងអង្គហេតុនៃរឿងក្ដី ០០៣ ដែលត្រូវបានចោទប្រកាន់ អាចមានប្រៀបលើភាពខុសគ្នានេះឡើយ។ QUB ឯកសារ D191/13 កថាខណ្ឌ ១៨ ដកស្រង់ទស្សនៈពី David Luban និង Hansdee Singh។ Luban គូសបញ្ជាក់ថា ធម្មនុញ្ញនៃសាលាក្ដីយោធាអន្តរជាតិ ("ធម្មនុញ្ញ IMT") សាលាក្ដីព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ("សាលាក្ដី ICTY") និង រវ៉ាន់ដា ("សាលាក្ដី ICTR") និង តុលាការព្រហ្មទណ្ឌអន្តរជាតិ ("តុលាការ ICC") តម្រូវដូចគ្នាឲ្យប្រជាជន *ស៊ីវិល* ជាជនគោលដៅនៃការវាយប្រហារ (David Luban *ទ្រឹស្ដីនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ* ២៩ Yale J. Int'l L. ៨៥, ១០៤ (ឆ្នាំ ២០០៤))។ Singh ពិភាក្សាត្រឹមតែសាលក្រមមួយរបស់សាលាក្ដី ICTY អំពីថាតើទាហានដែល *គ្មានលទ្ធភាពប្រយុទ្ធ* (hors de combat) អាចជា *ជនរងគ្រោះ* នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឬយ៉ាងណា (Hansdeep Singh *ការរិះគន់លើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង (សាលាក្ដី ICTY) ក្នុងរឿងក្ដី Mrksic៖ ការវាយតម្លៃសាជាថ្មីទៅលើថាតើទាហានដែល* គ្មានលទ្ធភាពប្រយុទ្ធ *មានសិទ្ធិទទួលបានការទទួលស្គាល់ជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឬយ៉ាងណា* (Critique of the Mrksic Trial Chamber (ICTY) Judgment: A Re-Evaluation on Whether Soldiers Hors de Combat Are Entitled to Recognition as Victims of Crimes Against Humanity) ៨ L.& Practice Int'l Cts & Tribs. ២៤៧ (ឆ្នាំ ២០០៩))។

[6] ដូចដែល Alexander Hamilton បានថ្លែង៖ "ការបង្កើតឧក្រិដ្ឋកម្មនៅក្រោយពេលការប្រព្រឹត្តនៃអង្គហេតុ ឬ និយាយម្យ៉ាងទៀត ការដាក់មនុស្សជាកម្មវត្ថុនៃការផ្តន្ទាទោសអំពីអ្វីដែលមិនរំលោភច្បាប់ នៅពេលដែលប្រព្រឹត្ត និង ទម្លាប់អនុវត្តន៍ដាក់ពន្ធនាគារដោយខុសច្បាប់ ក្នុងគ្រប់សម័យ គឺជាមធ្យោបាយសំណព្វ និង គួរឲ្យខ្លាចបំផុតនៃអំណាចផ្ដាច់ការ" The Federalist លេខ ៨៤ *ការជំទាស់ជាទូទៅ និង ខុសគ្នាមួយចំនួនទៅនឹងរដ្ឋធម្មនុញ្ញដែលត្រូវបានពិចារណា និង ឆ្លើយតប* (Certain General and Miscellaneous Objections to the Constitution Considered and Answered) (ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៧៨៨)។ ជាឧទាហរណ៍ គោលការណ៍នីត្យានុកូលភាពមានចែងក្នុងមាត្រា ១១(២) នៃសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស ("សេចក្ដីប្រកាស UDHR") មាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ("កតិកាសញ្ញា ICCPR") និង មាត្រា ៦៧ នៃអនុសញ្ញាទីក្រុងហ្សឺណែវ (IV)។

[7] *សូមមើល* Susan Lamb គ្មានបទល្មើស បើគ្មានច្បាប់ចែង គ្មានទណ្ឌកម្ម បើគ្មានច្បាប់ចែង (Nullum Crimen, Nulla Poena Sine Lege) *ក្នុងនីតិព្រហ្មទណ្ឌអន្តរជាតិ ក្នុង* ១ លក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ៖ សេចក្ដីអធិប្បាយ ៧៤៣ ៧៤៥-៧៤៦ (Cassese និង អ្នកផ្សេងទៀត បោះពុម្ពផ្សាយឆ្នាំ ២០០២) ដែលកត់សម្គាល់ថា ក្នុងតុលាការ *មិនអចិន្ត្រៃយ៍* សម័យទំនើប ក្ដីកង្វល់របស់មេធាវីការពារក្ដីអំពីគោលការណ៍នីត្យានុកូលភាព មានខ្លឹមសារធំធេង ទាក់ទងនឹងធាតុផ្សំបរិបទនៃឧក្រិដ្ឋកម្ម ដោយសារទំនោររបស់សាលាក្ដី ICTY និង ICTR ទៅរកការបកស្រាយបែបទូលាយនូវច្បាប់មនុស្សធម៌អន្តរជាតិ

គោលនយោបាយ និង សីលធម៌ មិនអាចទៅហួសពីច្បាប់ ឬ ជំនួសឱ្យច្បាប់ឡើយ នៅពេលដែលការអនុវត្តច្បាប់មិនទទួលបានលទ្ធផលដែលចង់បាននោះ។ ចៅក្រម Robertson ធ្វើការសង្កេតដោយសមហេតុផលថា៖ “វាច្បាស់ណាស់ថា នៅពេលដែលអំពើមានលក្ខណៈគួរឱ្យស្អប់ខ្ពើម និង រន្ធត់ខ្លាំង គោលការណ៍នីត្យានុកូលភាពត្រូវតែអនុវត្តយ៉ាងតឹងរ៉ឹងបំផុត ដើម្បីធានាបានថា ចុងចម្លើយមិនត្រូវបានផ្តន្ទាទោសដោយសារការស្អប់ខ្ពើម តែដោយសារភស្តុតាង ឬ មិនត្រូវបានផ្តន្ទាទោសពីឧក្រិដ្ឋកម្មដែលគ្មានរូបរាង។ គោលការណ៍ *គ្មានបទល្មើស [sic] បើគ្មានច្បាប់ចែង* (Nullem [sic] crimen) មិនអាចជាឃ្លាដែលគេយល់ជាទូទៅឡើយ ប៉ុន្តែវាដើរតួនាទីជាការការពារមួយចំនួនប្រឆាំងនឹងការសម្លាប់ដោយហ្វូងមហាជន”[8]។ គ្មានទម្លាប់អនុវត្តន៍របស់រដ្ឋ ឬ *ទស្សនៈច្បាប់* ក្នុងឆ្នាំ ១៩៧៥-១៩៧៩ បង្ហាញឱ្យឃើញថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិគ្រប

(“ច្បាប់ IHL”)។ *សូមមើលផងដែរ* Beth van Schaack គ្មានបទល្មើស បើគ្មានច្បាប់ចែង៖ *ការធ្វើច្បាប់តុលាការនៅចំណុចប្រសព្វនៃច្បាប់ និង សីលធម៌* (Crimen Sine Lege: Judicial Lawmaking at the Intersection of Law and Morals) ៩៧ Georgetown L.J. ១១៩, ១២១-១២៥, ១៨២ (ឆ្នាំ ២០០៨) ដែលផ្តល់យោបល់ថា ទោះបីជាចៅក្រមអន្តរជាតិបកស្រាយបែបទូលាយ និង អនុវត្តគោលការណ៍នីត្យានុកូលភាពក៏ដោយ ក៏ *ចុងចម្លើយសព្វថ្ងៃនេះ* បានទទួលការជូនដំណឹងគ្រប់គ្រាន់អំពីការវិវឌ្ឍន៍ថ្មីនៃយុត្តិសាស្ត្រដែរ។ ទោះជាយ៉ាងនេះក្តី ក្នុងរឿងក្តី “យុត្តិធម៌ប្រវត្តិសាស្ត្រ” ចំពោះមុខតុលាការជាតិ ឬ អ.វ.ត.ក. ដែល “កើតចេញពីសម័យសង្គ្រាមត្រជាក់ នៅពេលដែលការវិវឌ្ឍន៍ដែលពាក់ព័ន្ធក្នុងនីតិអន្តរជាតិទើបតែមានចលនា នៅពេលដែលចុងចម្លើយបានប្រព្រឹត្ត ការជំទាស់តវ៉ា NCSL អាចមានភាពស្រួចស្រាល់ជាងនេះ”។

[8] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* Norman សំណុំរឿងលេខ SCSL-2004-14-AR72(E) សេចក្តីសម្រេចលើញត្តិបឋមដែលផ្អែកលើកង្វះយុត្តាធិការ (ការជ្រើសរើសកុមារ) ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០០៤ យោបល់ជំទាស់របស់ចៅក្រម Robertson កថាខណ្ឌ ១២។ *សូមមើល ដូចខាងលើ កថាខណ្ឌ ៩* (“ការស្អប់ខ្ពើមតែមួយមុខមិនធ្វើឱ្យទង្វើនោះក្លាយជាឧក្រិដ្ឋកម្មក្នុងច្បាប់អន្តរជាតិឡើយ”) ១៤ (គោលការណ៍នីត្យានុកូលភាពជាគោលការណ៍សារវន្ត និង “ជាហេតុផលដែលយើងត្រូវបានគ្រប់គ្រងដោយច្បាប់ មិនមែនដោយនគរបាលនោះទេ”)។ *សូមមើលផងដែរ* រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Galić* សំណុំរឿងលេខ IT-98-29-A សាលក្រម ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០០៦ យោបល់ជំទាស់ដាច់ដោយឡែក និង មួយផ្នែករបស់ចៅក្រម Schomburg កថាខណ្ឌ ២១ (គូសបញ្ជាក់បន្ថែម)៖ “សាលាក្តីនេះមិនបានដើរតួនាទីជាអង្គនីតិបញ្ញត្តិឡើយ។ សាលាក្តីនេះមានកាតព្វកិច្ចអនុវត្តត្រឹមតែច្បាប់ទំនៀមទម្លាប់អន្តរជាតិជាធរមាននៅពេលមានអំពើល្មើស...។ *វានឹងធ្វើឱ្យខូចប្រយោជន៍មិនត្រឹមតែសាលាក្តីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងប៉ះពាល់ដល់ការវិវឌ្ឍន៍នៃនីតិព្រហ្មទណ្ឌអន្តរជាតិ និង យុត្តាធិការព្រហ្មទណ្ឌអន្តរជាតិ នាពេលអនាគតផងដែរ ប្រសិនបើយុត្តិសាស្ត្ររបស់យើងធ្វើឱ្យមើលឃើញថា ជាអ្នកបង្កើតឱ្យមានឧក្រិដ្ឋកម្ម - ដូច្នេះធ្វើឱ្យមុខងាររបស់ខ្លួនទៅជាបញ្ហានយោបាយ - ក្នុងករណីដែលទង្វើដែលជាបញ្ហាចោទ មិនត្រូវបានដាក់ទណ្ឌកម្ម ដោយគ្មានការសង្ស័យ នៅពេលដែលទង្វើនេះបានកើតឡើង”*។

ដណ្ដប់លើការវាយប្រហារទៅលើទាហានឡើយ[9]។ លិខិតុបករណ៍ដែលពាក់ព័ន្ធទាំងអស់ក្នុងឆ្នាំ ១៩៤៥-១៩៩៨ តម្រូវឱ្យមានប្រជាជន *ស៊ីវិល*[10]។

## ២. គោលបំណងនៃការបង្កើតឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺដើម្បីការពារជនស៊ីវិល

២. *អ្នកដែលមិនមែនភាគី* អះអាងថា ពាក្យ "ប្រជាជនស៊ីវិល" ត្រូវបកស្រាយបែបទូលាយ ពីព្រោះគោលបំណងនៃការបង្កើតឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺដើម្បីបំពេញចន្លោះប្រហោង ក្នុងផ្លូវដែលថាការរំលោភណាមួយដែលមិនមានចែងក្នុងច្បាប់សង្គ្រាម នឹងស្ថិតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[11]។ មិនត្រឹមត្រូវ។ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានបង្កើតឡើង ដើម្បីការពារ *ជនស៊ីវិល* ដែលមិនត្រូវបានការពារដោយច្បាប់សង្គ្រាម ប្រឆាំងនឹងអំពើដែលប្រព្រឹត្តទៅលើពួកគេពីសំណាក់រដ្ឋរបស់ពួកគេ។ ប្រភពដើមនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឆ្លុះបញ្ចាំងនូវបំណងប្រាថ្នាការពារប្រជាជនស៊ីវិល ដោយមិនគិតពីសញ្ជាតិ មិនមែនដើម្បីដាក់ជាបទល្មើសព្រហ្មទណ្ឌនូវទង្វើណាមួយដែលមិនត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មសង្គ្រាមនោះឡើយ[12]។ វិសាលភាពនៃឧក្រិដ្ឋកម្ម

---

[9] Saul ខកខានមិនបានផ្ដល់មូលដ្ឋានគាំទ្រការអះអាងរបស់គាត់ដែលថា និយមន័យទូលាយនៃ "ប្រជាជនស៊ីវិល" មិនបានរំលោភគោលការណ៍នីត្យានុកូលភាព និង អាចមើលឃើញជាមុនក្នុងឆ្នាំ ១៩៧៥-១៩៧៩។ *សូមមើល* Saul ឯកសារ D191/3 កថាខណ្ឌ ២២។ ផ្នែក ច *ខាងក្រោម* ពោលប្រាស្រ័យអំពីបញ្ហាដាច់ដោយឡែកថា តើទាហានអាចជា *ជនរងគ្រោះ* នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឬយ៉ាងណា។ បណ្ឌិត Williams និង Grey (ឯកសារ D191/11 កថាខណ្ឌ ២១-២២) អះអាងថា ទោះបីជាគ្មានមូលដ្ឋានសំអាងជាក់លាក់ក៏ដោយ ក៏ការទទួលស្គាល់ទាហានដែលជាគោលដៅរបស់រដ្ឋពួកគេផ្ទាល់ថា ជាជនស៊ីវិលក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នឹងស៊ីសង្វាក់ជាមួយនឹងច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ ១៩៧៥។ មិនត្រឹមត្រូវ។ អវត្តមាននៃមូលដ្ឋានសំអាងជាក់លាក់ ឆ្លុះបញ្ចាំងអំពីអវត្តមាននៃទម្លាប់អនុវត្តន៍របស់រដ្ឋ និង *ទស្សនៈច្បាប់* មិនមែនគ្រាន់តែថាបញ្ហានេះ "មិនទាន់កើតឡើងសម្រាប់ការធ្វើសេចក្ដីសម្រេច" នោះឡើយ។ *សូមមើល* ជើងទំព័រ ១២៣ *ខាងក្រោម*។

[10] *សូមមើល* សារណារបស់ មាស មុត ស្ដីពីសំណួរថា តើតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅឆ្នាំ ១៩៧៥-១៩៧៩ ការវាយប្រហារដោយរដ្ឋ ឬ អង្គការទៅលើកងកម្លាំងប្រដាប់អាវុធរបស់ខ្លួន អាចជាការវាយប្រហារដែលសំដៅលើប្រជាជនស៊ីវិលតាមគោលបំណងនៃមាត្រា ៥ នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក. ឬយ៉ាងណា ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០១៦ ឯកសារ D191/2 ("សារណា") កថាខណ្ឌ ៣-៧។

[11] Saul ឯកសារ D191/3 កថាខណ្ឌ ២០។ TRIAL ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០១៦ ឯកសារ D191/5 ("TRIAL ឯកសារ D191/5") កថាខណ្ឌ ២១-២២។ Rosenzweig ឯកសារ D191/7 ទំព័រ ៣ ៤ ៦។ Tsagourias ចុះថ្ងៃទី ១៧ ខែឧសភា ឆ្នាំ ២០១៦ ឯកសារ D191/9 ("Tsagourias ឯកសារ D191/9") កថាខណ្ឌ ២០-២១។ Wingdridge ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០១៦ ឯកសារ D191/10 ("Wingdridge ឯកសារ D191/10") កថាខណ្ឌ ៥ ៨ ២១។ Williams & Grey ឯកសារ D191/11 កថាខណ្ឌ ២០។

[12] *សូមមើល* ជើងទំព័រ ១២ នៃសារណា។

ប្រឆាំងមនុស្សជាតិមិនអាចត្រូវបានពង្រីក គ្រាន់តែដើម្បីបំពេញអ្វីដែលគេយល់ថា ជាចន្លោះប្រហោងក្នុងច្បាប់មនុស្សធម៌អន្តរជាតិ ("ច្បាប់ IHL") ឡើយ។

៣. គ្មានចន្លោះប្រហោង ឬ *ចន្លោះទំនេរ* (lacunae) ក្នុងច្បាប់ IHL សម្រាប់ទាហានផ្ទាល់របស់រដ្ឋឡើយ៖ ទាហានទាំងនេះត្រូវបានការពារដោយច្បាប់យោធាជាតិ[13] និង អាស្រ័យទៅតាមកាលៈទេសៈ ត្រូវបានការពារពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឬ ការរំលោភច្បាប់ IHL មួយចំនួន[14]។ និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងធម្មនុញ្ញ IMT និង លិខិតុបករណ៍ជាបន្តបន្ទាប់បង្ហាញឲ្យឃើញពីចំណាប់អារម្មណ៍ និង ចេតនារបស់រដ្ឋចង់រក្សាទុកលទ្ធភាពដោះស្រាយជាលក្ខណៈផ្ទៃក្នុងជាមួយនឹងទាហានរបស់ខ្លួន[15]។ ថាតើការដកទាហានចេញពីនិយមន័យនៃប្រជាជនស៊ីវិល ស្របជាមួយលិខិតុបករណ៍សិទ្ធិមនុស្សឬយ៉ាងណានោះ គឺមិនមានសារៈសំខាន់ឡើយ[16]។ បញ្ហាចោទដែលពាក់ព័ន្ធ គឺឋានៈតាមទំនៀមទម្លាប់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងឆ្នាំ ១៩៧៥-១៩៧៩។ លិខិតុបករណ៍ដែលពាក់ព័ន្ធទាំងអស់ក្នុងរយៈកាលនោះ ផ្ទុយពីការអះអាងរបស់

---

[13] TRIAL (ឯកសារ D191/5 កថាខណ្ឌ ២២ ជើងទំព័រ ៣៥) ដកស្រង់ Antonio Cassese ដើម្បីគាំទ្រទឡ្ហីករណ៍របស់ខ្លួនដែលថា ការដាក់បញ្ចូលទាហានរបស់រដ្ឋទៅក្នុងអត្ថន័យនៃពាក្យ "ប្រជាជនស៊ីវិល" គឺស៊ីសង្វាក់ជាមួយនឹងភាពសមហេតុផលខាងដើម ដែលនៅពីក្រោយឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ Cassese *មិនបាន* គាំទ្រទឡ្ហីករណ៍នេះឡើយ។ ANTONIO CASSESE ទម្រង់មនុស្សនៃច្បាប់អន្តរជាតិ (THE HUMAN DIMENSION OF INTERNATIONAL LAW) ឯកសារជ្រើសរើស ៤៥៦ (ឆ្នាំ ២០០៨) (គូសបញ្ជាក់បន្ថែមនៅឃ្លាចុងក្រោយ)៖ ភាពសមស្របនៃវិសាលភាពមានកម្រិតនៃមាត្រា ៦ (គ) គឺថា យុទ្ធជន *ខ្លាំង* ត្រូវបានការពាររួចហើយដោយច្បាប់ទំនៀមទម្លាប់សង្គ្រាម ខណៈដែលវាមិនទំនងថាយុទ្ធការីអាចប្រព្រឹត្តអំពើឃោរឃៅទៅលើយោធា *របស់ខ្លួន* ឬ យោធារបស់ប្រទេស *សម្ព័ន្ធមិត្ត។ ក្នុងគ្រប់ករណីទាំងអស់ អំពើឃោរឃៅបែបនេះ ប្រសិនបើមាន នឹងត្រូវស្ថិតក្រោមយុត្តាធិការនៃតុលាការសឹកនៃប្រទេសដែលពាក់ព័ន្ធនោះ។ និយាយម៉្យាងទៀត ពួកគេនឹងត្រូវស្ថិតនៅក្រោមបញ្ញត្តិនៃច្បាប់* ជាតិ។

[14] *សូមមើល* សារណា កថាខណ្ឌ ២១ កថាខណ្ឌ ២៣។

[15] *សូមមើល ដូចខាងលើ* កថាខណ្ឌ ១៦-២១។

[16] Williams & Grey (ឯកសារ D191/11 កថាខណ្ឌ ២០) អះអាងថា ការខកខានមិនបានចាត់ទុកសមាជិកនៃកម្លាំងប្រដាប់អាវុធរបស់រដ្ឋ ជាជនស៊ីវិលក្នុងពេលមានសន្តិភាព នឹងមិនស៊ីសង្វាក់ឡើយជាមួយកម្មវត្ថុ និង គោលបំណងនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង លិខិតុបករណ៍សិទ្ធិមនុស្ស ដូចជា អនុសញ្ញាប្រឆាំងនឹងទារុណកម្ម ដែលមិនបំបែកជនស៊ីវិលចេញពីជនមិនមែនស៊ីវិល។ *អ្នកដែលមិនមែនជាភាគីនេះ* ដកស្រង់ Cassese ដើម្បីគាំទ្រទឡ្ហីករណ៍របស់ខ្លួន។ *សូមមើល* ANTONIO CASSESE នីតិព្រហ្មទណ្ឌអន្តរជាតិ ៨៧ ១០៤ (សារព័ត៌មានសកលវិទ្យាល័យ Oxford បោះពុម្ពផ្សាយលើកទីបី ឆ្នាំ ២០១៣)។ Cassese មិនបានដកស្រង់ឯកសារសំអាងណាមួយសម្រាប់គាំទ្រសេចក្តីថ្លែងរបស់គាត់ អំពីការវិវឌ្ឍន៍នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ។ ការកំណត់ដែលពាក់ព័ន្ធគឺ តើអ្វីជានិយមន័យតាមទំនៀមទម្លាប់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងឆ្នាំ ១៩៧៥-១៩៧៩ មិនមែនជាអ្វីដែលបញ្ញាវ័ន្តច្បាប់ចាត់ទុកថាជានិយមន័យក្នុងទសវត្សរ៍ឆ្នាំ ២០០០ ឡើយ។ *សូមមើលផងដែរ* ផ្នែក ឃ *ខាងក្រោម*។

TRIAL[17] រួមទាំងសេចក្តីព្រាងក្រមឆ្នាំ ១៩៥៤ ស្តីពីបទល្មើសផងដែរ តម្រូវឱ្យមានប្រជាជន *ស៊ីវិល*[18]។

**ខ. វាពុំមែនមិនសមហេតុផលនោះទេ ក្នុងការបកស្រាយពាក្យ "ប្រជាជនស៊ីវិល" ថាដក ទាហានចេញនោះ**

៤. *អ្នកដែលមិនមែនភាគី* អះអាងថា ការបកស្រាយពាក្យ "ប្រជាជនស៊ីវិល" ថាមិនរាប់បញ្ចូល ទាហានរបស់រដ្ឋ នឹងបណ្តាលឱ្យមានលទ្ធផលដែលមិនអាចទទួលយកបាន[19]។ មិនគួរឱ្យជឿជាក់បាន។ វាពុំមែនមិនសមហេតុផលឡើយ ក្នុងការពិចារណាថា រដ្ឋចង់ឱ្យទង្វើរបស់ខ្លួនចំពោះ ទាហានរបស់ខ្លួន ត្រូវបានគ្រប់គ្រងដោយវិធានផ្ទៃក្នុង ជាជាងដោយនីតិព្រហ្មទណ្ឌអន្តរជាតិ ("ច្បាប់ ICL") នោះ។ ទាហាន គឺខុសគ្នាពីជនស៊ីវិល ដោយសារហេតុផលផ្សេងៗជាច្រើន ប៉ុន្តែ ជាពិសេស ដោយសារតែមុខងាររបស់ពួកគេនៅក្នុងសង្គមស៊ីវិល[20]។

៥. Tsagourias មិនបានដកស្រង់ឯកសារសំអាងណាមួយ ដើម្បីគាំទ្រការអះអាងរបស់ខ្លួនដែលថា មានភាពមិនអាចទទួលយកបានកើតចេញមកពីការដកទាហានរបស់រដ្ឋចេញពី "ប្រជាជនស៊ីវិល" នោះឡើយ[21]។ Saul ដកស្រង់ដោយមិនត្រឹមត្រូវនូវរឿងក្តី *ឌុច* និង រឿងក្តី *Fofana និង អ្នកផ្សេង*

---

[17] Trial ឯកសារ D191/5 កថាខណ្ឌ ២២។

[18] *សូមមើល* សារណា កថាខណ្ឌ ៤-៧។ មាត្រា ២(១១) នៃសេចក្តីព្រាងក្រមស្តីពីបទល្មើស ឆ្នាំ ១៩៥៤ ដែលផ្តល់និយមន័យ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បានបញ្ចូលពាក្យ ( គូសបញ្ជាក់បន្ថែម)៖ "ដែលត្រូវបានប្រព្រឹត្តិទៅលើ *ប្រជាជនស៊ីវិល* ទាំងឡាយ ...."។

[19] Saul ឯកសារ D191/3 កថាខណ្ឌ ៣(ឃ) កថាខណ្ឌ ២១។ Tsagourias ឯកសារ D191/9 កថាខណ្ឌ ២២។

[20] *សូមមើល រឿងក្តី Engel និង អ្នកផ្សេងទៀត តទល់នឹង ប្រទេសហូឡង់* លេខ ៥១00/៧១, ៥១0១/៧១, ៥១0២/៧១, ៥៣៥៤/៧២, ៥៣៧0/៧២ ចុះថ្ងៃទី ៨ ខែមិថុនា ឆ្នាំ ១៩៧៦ ស៊េរី ក លេខ ២២ § ៥៤ និង យោបល់រួមដាច់ដោយឡែករបស់ ចៅក្រម O'Donoghue និង ចៅក្រម Pedersen៖ "តាមការយល់ឃើញរបស់យើង មានភាពខុសគ្នាច្បាស់លាស់រវាងកាតព្វកិច្ចរបស់ពលរដ្ឋទូទៅ ក្នុងការគោរពច្បាប់ និង ឋានៈពិសេសនៃបុគ្គលិកយោធា ក្នុងការគោរពក្រមវិន័យ ដែលជាធាតុផ្សំសំខាន់ ចាំបាច់ និង ជាមូលដ្ឋាននៃកងកម្លាំងដែលពួកគេជាសមាជិក... មានកត្តាបឋមដែលគួរពិនិត្យមើលក្នុងរចនាសម្ព័ន្ធ និង លក្ខណៈនៃការបង្កើតយោធាក្នុងប្រទេសដែលជាភាគីនៃអនុសញ្ញានេះ។ កត្តានេះ គឺក្រមវិន័យ ដែលការគោរពក្រមនេះ គឺចាំបាច់សំខាន់ សម្រាប់ការបន្តអត្ថិភាពនៃកងកម្លាំងប្រដាប់អាវុធ និង ខុសគ្នាឆ្ងាយពីស្ថាប័ន ឬ សមាគមដទៃទៀត ដែលមានបំណងចង់អនុវត្តវិធានការវិន័យទៅលើសមាជិករបស់ខ្លួន"។

[21] Tsagourias ឯកសារ D191/9 កថាខណ្ឌ ២0-២២។

*ទៀត*[22]។ រឿងក្តី *ឌុច* បានទទួលយកអត្ថន័យសាមញ្ញនៃពាក្យ "ជនស៊ីវិល" ដោយសម្រេចថា សមាជិកកងកម្លាំងប្រដាប់អាវុធ មិនមែនទទួលបានឋានៈជាជនស៊ីវិល គ្រាន់តែដោយសារពួកគេមិនកាន់អាវុធ ឬ មិនបានចូលរួមក្នុងការប្រយុទ្ធនោះឡើយ[23]។ រឿងក្តី *Fofana និង អ្នកផ្សេងទៀត* បានសម្រេចថា កងកម្លាំងនគរបាលមិនមែនជាជនស៊ីវិលឡើយតាមច្បាប់ IHL *នៅពេលដែលពួកគេស្ថិតក្រោមការគ្រប់គ្រងរបស់យោធា*[24] ដោយទទួលស្គាល់ភាពខុសគ្នារវាងទាហាន និង ជនស៊ីវិល។ វាពុំមែនមិនសមហេតុផលឡើយ ក្នុងការអនុវត្តភាពខុសគ្នានេះចំពោះទាហានរបស់រដ្ឋធៀបនឹងជនស៊ីវិលរបស់រដ្ឋនោះ។

**គ. ទាហានខុសគ្នាពីជនស៊ីវិល**

**១. ក្នុងពេលមានសន្តិភាព ភាពខុសគ្នាផ្លូវច្បាប់រវាងទាហាន និង ជនស៊ីវិល នៅតែមាន ហើយ "ប្រជាជនស៊ីវិល" មានអត្ថន័យច្បាស់លាស់ដូចគ្នាក្នុងពេលមានសង្គ្រាម**

៦. *អ្នកដែលមិនមែនភាគី* អះអាងថា គ្មានភាពខុសគ្នាផ្លូវច្បាប់រវាងទាហាន និង ជនស៊ីវិលក្នុងពេលមានសន្តិភាពឡើយ ពីព្រោះគ្មានយុទ្ធជន ភាពចាំបាច់ដែលជាមូលដ្ឋាននៃគោលការណ៍ភាពខុសគ្នានេះមិនអនុវត្តឡើយ ហើយទាហានស្ថិតក្រោមការការពារ និង ច្បាប់ ដូចគ្នានឹងជនស៊ីវិល[25]។ មិនត្រឹមត្រូវ។ យើងមិនអាចគ្រាន់តែថ្លែងថា ដោយសារមានភាពខុសគ្នានៅក្នុងច្បាប់អន្តរជាតិរវាងទាហាន និង ជនស៊ីវិល ក្នុងអំឡុងពេលសង្គ្រាម មិនមានភាពខុសគ្នាបែបនេះក្នុងពេលមានសន្តិភាព

---

[22] Saul ឯកសារ D191/3 កថាខណ្ឌ ២១។

[23] រឿងក្តី *កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ជ សាលក្រម ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ២០១០ ឯកសារ E188 កថាខណ្ឌ ៣០៥។ *សូមមើលផងដែរ* រឿងក្តី *នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ជ សាលក្រមរឿងក្តី ០០២/០១ ចុះថ្ងៃទី ៧ ខែសីហា ឆ្នាំ ២០១៤ ឯកសារ E313 កថាខណ្ឌ ១៨៥-១៨៦។

[24] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Fofana និង អ្នកផ្សេងទៀត* សំណុំរឿងលេខ SCSL-04-41-A សាលក្រម ចុះថ្ងៃទី ២៨ ខែឧសភា ឆ្នាំ ២០០៨ កថាខណ្ឌ ២៦០។ Saul ដកស្រង់ខុសសំដីអង្គជំនុំជម្រះតុលាការកំពូល។ *សូមមើល* Saul ឯកសារ D191/3 ជើងទំព័រ ៣០។

[25] Saul ឯកសារ D191/3 កថាខណ្ឌ ៧-១៤។ Drummond និង អ្នកផ្សេងទៀត ឯកសារ D191/4 កថាខណ្ឌ ១៨-១៩។ Nicholson ឯកសារ D191/8 ទំព័រ ១ កថាខណ្ឌ ៣។ Tsagourias ឯកសារ D191/9 កថាខណ្ឌ ១៨-១៩។ Windride ឯកសារ D191/10 កថាខណ្ឌ ១៦។ Williams & Grey ឯកសារ D191/11 កថាខណ្ឌ ១៩-២០។

នោះឡើយ។ ភាពខុសគ្នាផ្លូវច្បាប់រវាងទាហាន និង ជនស៊ីវិល មានអត្ថិភាពក្នុងពេលមានសន្តិភាព និង សង្គ្រាម[26]។ ទាហានតែងតែស្ថិតនៅក្រោមច្បាប់ និង ក្រមវិជ្ជាជីវៈផ្សេងពីជនស៊ីវិល[27]។

៧. Nicholson មិនបានដកស្រង់ឯកសារសំអាងណាមួយគាំទ្រការអះអាងរបស់គាត់ដែលថា គ្មានភាពខុសគ្នាផ្លូវច្បាប់រវាងទាហាន និង ជនស៊ីវិលក្នុងពេលមានសន្តិភាពឡើយ[28]។ Tsagourias ដកស្រង់ដោយមិនត្រឹមត្រូវនូវសំដីរបស់ចៅក្រមប្រធាន Mansfield[29]។ Mansfield មិនបានថ្លែងថា គ្មានភាពខុសគ្នារវាងទាហាន និង ជនស៊ីវិលក្នុងពេលមានសន្តិភាពឡើយ គ្រាន់តែថា ទាហាននៅតែជាពលរដ្ឋរបស់រដ្ឋពួកគេ នៅខណៈដែលពួកគេជាទាហាន។ សមហេតុផល។ ការណ៍ដែលទាហាននៅមានករណីយកិច្ចជាពលរដ្ឋ មិនមែនមានន័យថា ពួកគេស្ថិតនៅក្រោមច្បាប់ព្រហ្មទណ្ឌដូចគ្នានឹងជនស៊ីវិលឡើយ ឬ ថា មិនមានភាពខុសគ្នាក្នុងពេលមានសន្តិភាពរវាងទាហាន និង ជនស៊ីវិលឡើយ[30]។

---

[26] *សូមមើល ឧទាហរណ៍* ជើងទំព័រ ២១ *ខាងលើ* អំពីយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប។

[27] *សូមមើល* សារណា កថាខណ្ឌ ១៧។ *សូមមើលផងដែរ ឧទាហរណ៍* មាត្រា ៤ នៃសេចក្តីបង្គាប់របស់កម្ពុជាទាក់ទងនឹងក្រុមប្រឹក្សាសង្គ្រាម (ថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ១៩៧៣) ដែលចែងអំពីសមត្ថកិច្ចក្នុងការកាត់សេចក្តីទាហានដែលប្រព្រឹត្តិបទល្មើស និង មាត្រា ៣ ដែលរៀបរាប់អំពីបទល្មើសនានា។ ច្បាប់កងទ័ព [ចក្រភពអង់គ្លេស] ឆ្នាំ ១៩៥៥ ៣ និង ៤ Eliz. ២ Ch. ១៨ §§ ២៥-១៤៣, ២០៥-១៣ ដែលចែងអំពីប្រភេទបុគ្គល ដែលស្ថិតនៅក្រោមច្បាប់នេះ និង នីតិវិធីសម្រាប់ការជំនុំជម្រះ និង ការដាក់ទណ្ឌកម្មបទល្មើស ដែលប្រព្រឹត្តដោយជនទាំងឡាយណាដែលស្ថិតក្រោមច្បាប់នេះ។

[28] Nicholson ឯកសារ D191/8 ទំព័រ ១ កថាខណ្ឌ ៣ ដែលក្នុងនោះគាត់បានទទួលស្គាល់ថា តុលាការសិទ្ធិមនុស្សអឺរ៉ុបបានចែកដាច់ពីគ្នារវាងជនស៊ីវិល និង ទាហាន។ *ដូចខាងលើ* ជើងទំព័រ ១។ *សូមមើលផងដែរ* ជើងទំព័រ ២០ *ខាងលើ* ។

[29] Tsagourias ឯកសារ D191/9 កថាខណ្ឌ ១៨ ដែលដកស្រង់ Mansfield ដើម្បីគាំទ្រទស្សនៈដែលថា ទាហានស្ថិតនៅក្រោមច្បាប់ព្រហ្មទណ្ឌដូចគ្នានឹងជនស៊ីវិលក្នុងពេលមានសន្តិភាព និង មិនមានអភ័យឯកសិទ្ធិបន្ថែម។

[30] Mansfield បានថ្លែងថា ក្នុងនាមជាពលរដ្ឋ ទាហានមានករណីយកិច្ចទប់ស្កាត់បទល្មើស។ ពួកគេមិនត្រូវឈរមើលឡើយ នៅពេលការរំលោភសន្តិភាព ឬ បទល្មើសកំពុងកើតឡើង ដោយសារមេបញ្ជាការរបស់ពួកគេ ឬ មន្ត្រីតុលាការ (Justice of the Peace) មិនមានវត្តមាននោះ។ *សូមមើល* CAPTAIN THOMAS FREDERICK SIMMONS, R.A កំណត់សម្គាល់ស្តីពីរដ្ឋធម្មនុញ្ញ និង ទម្លាប់អនុវត្តន៍របស់តុលាការសឹក ៤០៤ កថាខណ្ឌ ១០៩៧ (J. Murray ឆ្នាំ ១៨៦៣)។ ក្បួនច្បាប់យោធា ២០៨ ជើងទំព័រ (ក) (ការិយាល័យសង្គ្រាម បោះពុម្ពលើកទី ៥ ឆ្នាំ ១៩០៧) ("ក្បួន")។ ក្បួននេះកត់សម្គាល់ថា ច្បាប់អង់គ្លេសខុសពីប្រទេសផ្សេងទៀត ទាក់ទងនឹងទំនាក់ទំនងរបស់មន្ត្រីរដ្ឋ និង ទាហាន ទៅនឹងជីវិតជនស៊ីវិល និង សិទ្ធិ និង ករណីយកិច្ចពលរដ្ឋរបស់ទាហាន គឺចាំបាច់ត្រូវស្ថិតក្រោមការកំហិត ដើម្បីអនុញ្ញាតឲ្យគាត់បំពេញករណីយកិច្ចរបស់គាត់ចំពោះរដ្ឋ ( The Crown)។ ក្បួន នៅត្រង់ ២០៨ កថាខណ្ឌ ១-២។

៨. សាស្ត្រាចារ្យ Drummond និង អ្នកផ្សេងទៀត សំអាងលើពិធីសារបន្ថែម I[31] ដើម្បីអះអាងថា ដូចនឹងទាហានរបស់រដ្ឋមិនពាក់ព័ន្ធក្នុងជម្លោះ ដែលមិនមែនជាយុទ្ធជនតាមច្បាប់ IHL គ្មានយុទ្ធជនទេក្នុងពេលមានសន្តិភាព។ ហេតុដូច្នេះ ទាហានជាជនស៊ីវិល[32]។ មិនគួរឱ្យជឿជាក់បាន។ ភាពមិនអាចអនុវត្តបាននៃច្បាប់ IHL នៅពេលមានសន្តិភាព មិនមែនមានន័យថា ក្នុងពេលមានសន្តិភាព *គ្មាន* ស្ថាប័នច្បាប់ណាបែងចែកខុសគ្នារវាងទាហាន និង ជនស៊ីវិល ឬ ថា មិនមានភាពខុសគ្នារវាងអត្ថន័យធម្មតានៃពាក្យទាំងនេះនោះទេ។

៩. Drummond និង អ្នកផ្សេងទៀត ដកស្រង់យុត្តិសាស្ត្ររ៉ូម៉ានី អាហ្សង់ទីន និង អេស្ប៉ាញ[33]។ មិនសមហេតុសមផល។ តុលាការរ៉ូម៉ានីបានសម្រេចថា សមាជិកយោធាខ្លះដែលត្រូវបានដាក់ពន្ធគារគឺជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនមែនសម្រេចថា ពួកគេជាប្រជាជនគោលដៅនៃការវាយប្រហារនោះទេ[34]។ ជាងនេះទៅទៀត ក្រមព្រហ្មទណ្ឌរ៉ូម៉ានី ឆ្នាំ ១៩៦៩ មិនបានប្រើប្រាស់និយមន័យតាមទំនៀមទម្លាប់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ[35]។ រឿងក្តីអាហ្សង់ទីនដែលជាក់ស្តែងត្រូវបានប្តឹងតាមច្បាប់ក្រោយឆ្នាំ ១៩៧៩[36] មិនពាក់ព័ន្ធនឹងការផ្តន្ទាទោសពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ ប៉ុន្តែផ្តន្ទាទោសពីបទមនុស្សឃាត ការធ្វើទារុណកម្ម និង ការរំលោភ

---

[31] ពិធីសារបន្ថែមលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៤៩ ដែលទាក់ទងនឹងការការពារជនរងគ្រោះនៃជម្លោះប្រដាប់អាវុធអន្តរជាតិ ១១២៥ UNTS ៣ ចុះថ្ងៃទី ៨ ខែមិថុនា ឆ្នាំ ១៩៧៧ ("ពិធីសារបន្ថែម I")។

[32] Drummond និង អ្នកផ្សេងទៀត ឯកសារ D191/4 កថាខណ្ឌ ១៨-១៩។

[33] *ដូចខាងលើ* កថាខណ្ឌ ២០។

[34] *សូមមើល* ឯកសារ D191/4.1.28 ដែលដកស្រង់តុលាការជាន់ខ្ពស់កំពូល និង យុត្តិធម៌ (High Court of Cassation and Justice) រឿងក្តីលេខ ៣៩៨៦/២/២០១៤ ទំព័រ ៣ ទំព័រ ១០៤-៤១។

[35] យោងតាម *អ្នកដែលមិនមែនជាភាគី* បញ្ញត្តិនេះជាមាត្រា ៣៥៨ (១) និង (៣) នៃក្រមព្រហ្មទណ្ឌរ៉ូមានី ឆ្នាំ ១៩៦៩ (ការបកប្រែជាភាសាអង់គ្លេសនៅលើអ៊ិនធឺណែត)៖ "(១) ការដាក់ជនរងរបួស ឬ អ្នកជំងឺ សមាជិកនៃបុគ្គលិកសុខាភិបាលស៊ីវិល ឬ បុគ្គលិកកាកបាទក្រហម ឬ អង្គការដូចគ្នានេះ ជនភៀសខ្លួន ឈ្លើយសឹក និង ជាទូទៅ ជនដទៃទៀតដែលបានធ្លាក់ចូលក្នុងដៃរបស់សត្រូវ ឱ្យស្ថិតក្រោមអំពើអមនុស្សធម៌ ឬ ការពិសោធន៍វេជ្ជសាស្ត្រ ឬ វិទ្យាសាស្ត្រ ដែលពុំផ្តល់យុត្តិកម្មដោយការព្យាបាលវេជ្ជសាស្ត្រ ដើម្បីឧត្តមប្រយោជន៍របស់ពួកគាត់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ ឆ្នាំ ទៅ ២០ ឆ្នាំ និង ហាមឃាត់សិទ្ធិមួយចំនួន ..."។ រយៈពេលនៃដាក់ពន្ធនាគារនេះហាក់ដូចជាត្រូវបានកែប្រែនៅក្រោយឆ្នាំ ១៩៦៩។

[36] ប្រហែលជាច្បាប់ ឆ្នាំ១៩៩៥ ដែលផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីការមិនអនុវត្តអាជ្ញាយុកាលចំពោះឧក្រិដ្ឋកម្មសង្គ្រាម និង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ *សូមមើល* ឯកសារ D191/4.1.29 ទំព័រ ៣ ដែលដកស្រង់សាលក្រម និង យោងទំព័រ ១៩៨២ និង ទំព័រ ១៩៨៦ នៃសាលក្រមនោះ។

អំណាចសាធារណៈតាមច្បាប់ជាតិ[37]។ Pinochet ត្រូវបានចោទប្រកាន់ពីបទភេរវកម្ម ដែលជាឧក្រិដ្ឋកម្មទោល និង ពីបទប្រល័យពូជសាសន៍ និង ការធ្វើទារុណកម្ម[38]។ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនត្រូវបានហាមឃាត់ឡើយនៅក្នុងក្រមព្រហ្មទណ្ឌរបស់ប្រទេសអេស្ប៉ាញនៅពេលនោះ[39]។ សេចក្តីសម្រេចទាំងនេះចង្អុលបង្ហាញថា ជនមិនមែនស៊ីវិលអាចជាជនរងគ្រោះនៃឧក្រិដ្ឋកម្ម (ឧក្រិដ្ឋកម្មខ្លះត្រូវបានពិពណ៌នាថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ) មិនមែនចង្អុលបង្ហាញថាជនមិនមែនស៊ីវិលអាចជាប្រជាជនគោលដៅនៃការវាយប្រហារ ក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ។ សេចក្តីសម្រេចទាំងនេះមិនមានប្រយោជន៍ ឬ ទាក់ទងនឹងទម្លាប់អនុវត្តន៍របស់រដ្ឋ ឬ *ទស្សនៈច្បាប់* ទាក់ទងនឹងនិយមន័យតាមទំនៀមទម្លាប់នៃពាក្យ "ប្រជាជនស៊ីវិល" ក្នុងឆ្នាំ ១៩៧៥-១៩៧៩ ឡើយ។

១០. និយមន័យនៃពាក្យ "ជនស៊ីវិល" ក្នុងពេលមានសន្តិភាពក្នុងរឿងក្តី *Kayishema* គឺគួរជាទីពេញចិត្ត[40]។ និយមន័យនេះបានអនុវត្តនៅតំបន់ Kibuye ដែលគ្មានជម្លោះប្រដាប់អាវុធ[41] និង ស្របជាមួយនិយមន័យនៃកងកម្លាំងប្រដាប់អាវុធក្នុងពិធីសារបន្ថែម I[42]។ ពិធីសារបន្ថែម II ដែលទាក់ទង

---

[37] *ដូចខាងលើ* ទំព័រ ៣។ *សូមមើលផងដែរ* ក្រមព្រហ្មទណ្ឌអាហ្សង់ទីន (ច្បាប់លេខ ១១.១៧៩ (ឆ្នាំ ១៩៨៤)) មាត្រា ៨០(២)-(៤) មាត្រា ៨១(ខ) មាត្រា ១៤៤*ស្ទួន* មាត្រា ១៤៤*ស្ទួនពីរ* សម្រាប់និយមន័យនៃបទល្មើសទាំងនេះ។

[38] *សូមមើល* សេចក្តីណែនាំនៃតុលាការកណ្តាល សេចក្តីសង្ខេប ១៩/៩៧ បទបញ្ជាស្តីពី "ប្រតិបត្តិការសត្វត្មាត" (Condor Operation) ចុះថ្ងៃទី ៣ ខែធ្នូ ឆ្នាំ ១៩៩៨ ទំព័រ ៤០។

[39] Drummond និង អ្នកផ្សេងទៀត (ឯកសារ D191/4 កថាខណ្ឌ ២០) អះអាងដោយពុំត្រឹមត្រូវថា Pinochet ត្រូវបានចោទប្រកាន់ពីបទល្មើសជាមូលដ្ឋាននៃអំពើភេរវកម្ម ជាផ្នែកមួយនៃប្រភេទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ បទល្មើសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានដាក់បន្ថែមចូលទៅក្នុងក្រមព្រហ្មទណ្ឌ នៅឆ្នាំ ២០០៣។ *សូមមើល* ច្បាប់លេខ ១៥/២០០៣ ចុះថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ២០០៣ ដែលធ្វើវិសោធនកម្មក្រមព្រហ្មទណ្ឌ ដែលត្រូវបានហៅផងដែរថា ច្បាប់រៀបចំអង្គការ (Organic Law) លេខ ១០/១៩៩៥ ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ១៩៩៥។

[40] Drummond និង អ្នកផ្សេងទៀត អះអាងថា និយមន័យនេះមិនគួរជាទីគាប់ចិត្តនោះទេ ពីព្រោះអង្គជំនុំជម្រះសាលាដំបូងមានភាពមិនស៊ីសង្វាក់គ្នាក្នុងស្វែងរកនិយមន័យទូលំទូលាយ ប៉ុន្តែក្រោយមកប្រើប្រាស់និយមន័យចង្អៀតជាង និយមន័យនៅក្នុងច្បាប់ IHL។ Drummond និង អ្នកផ្សេងទៀត ឯកសារ D191/4 កថាខណ្ឌ ២១។

[41] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Kayishema & Ruzindana* សំណុំរឿងលេខ ICTR-95-1-T សាលក្រម ចុះថ្ងៃទី ២១ ខែឧសភា ឆ្នាំ ១៩៩៩ កថាខណ្ឌ ១២៧ ("*រឿងក្តី Kayishema*")។

[42] មាត្រា ៥០ កំណត់និយមន័យជនស៊ីវិលដោយយោងនិយមន័យនៃកងកម្លាំងប្រដាប់អាវុធក្នុងមាត្រា ៤៣ ដែលដាក់បញ្ចូល *ក្នុងចំណោមនោះ* ភ្នាក់ងារអនុវត្តច្បាប់រដ្ឋដែលត្រូវបានបញ្ចូលទៅក្នុងកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋ។ *សូមមើល* មាត្រា ៤៣ មាត្រា ៥០ នៃពិធីសារបន្ថែម I។

នឹងជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិ (ឧទាហរណ៍ ប្រទេសរវ៉ាន់ដា)[43] ដាក់បញ្ចូលនិយមន័យរបស់ពិធីសារបន្ថែម I[44]។ អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តនិយមន័យដែលស្របនឹងពិធីសារបន្ថែម I ពិធីសារបន្ថែម II និង អត្ថន័យធម្មតានៃពាក្យ "ជនស៊ីវិល"[45]។ ដោយមិនដកស្រង់ឯកសារសំអាងណាមួយ Tsagourias អះអាងថា និយមន័យនេះ គឺទូទៅ និង មានភាពជាក់លាក់តាមកាលៈទេសៈ[46]។ ប៉ុន្តែនៅពេលគ្មានជម្លោះប្រដាប់អាវុធ អង្គជំនុំជម្រះសាលាដំបូងបានឲ្យនិយមន័យពាក្យ "ជនស៊ីវិល" ថាមិនរាប់បញ្ចូលទាហាន។ *អ្នកដែលមិនមែនជាភាគី* មិនបានបង្ហាញឲ្យឃើញពីហេតុផលដែលថានិយមន័យនេះមិនសមស្របនោះឡើយ។

១១. វាគ្មានសារៈសំខាន់ផ្នែកទស្សនទានឡើយដែលថា គណៈប្រតិភូដែលពាក់ព័ន្ធនឹងការធ្វើសេចក្តីព្រាងលក្ខន្តិកៈតុលាការ ICC បានជឿជាក់ថា ពាក្យ "ជនស៊ីវិល" មានន័យមិនច្បាស់លាស់ និង នាំឲ្យភ័ន្តច្រឡំ ពីព្រោះពាក្យនេះបានសឲ្យឃើញពីទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ[47]។ រដ្ឋចំនួន ១៦០ បានពាក់ព័ន្ធនឹងការធ្វើសេចក្តីព្រាងលក្ខន្តិកៈនេះក្នុងរយៈពេល ៣ ឆ្នាំ[48]។ និយមន័យដែលទទួលបានការឯកភាពជាចុងក្រោយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បានតម្រូវឲ្យការវាយប្រហារត្រូវតែសំដៅទៅលើ *ប្រជាជនស៊ីវិល* ដូចដែលតម្រូវដោយច្បាប់ទំនៀមទម្លាប់អន្តរជាតិ[49]។

---

[43] អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា គ្មានជម្លោះប្រដាប់អាវុធនៅតំបន់ Kibuye ឡើយ ប៉ុន្តែថា ជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិបានកើតឡើងនៅក្នុងដែនដីប្រទេសរវ៉ាន់ដា។ *រឿងក្តី Kayishema* កថាខណ្ឌ ១៧២។

[44] *សូមមើល* មាត្រា ១(១) នៃពិធីសារបន្ថែមលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៤៩ ដែលទាក់ទងនឹងការការពារជនរងគ្រោះនៃជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិ ចុះថ្ងៃទី ៨ ខែមិថុនា ឆ្នាំ ១៩៧៧ ១១២៥ UNTS ៦០៩។

[45] និយមន័យនេះនៅតែទទួលការគាំទ្រនាពេលបច្ចុប្បន្ន។ *សូមមើល* មហាសន្និបាត អ.ស.ប. Int'l Law Comm'n Rep (ILC) *របាយការណ៍ទីមួយស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ* ឯកសារ អ.ស.ប. A/CN.4/680 (ចុះថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ ២០១៥) កថាខណ្ឌ ១៣៥៖ "ក្នុងអំឡុងពេលមានសន្តិភាព 'ជនស៊ីវិល' ត្រូវរួមបញ្ចូលជនទាំងអស់ លើកលែងតែបុគ្គលទាំងឡាយណាដែលមានករណីយកិច្ចថែរក្សាសណ្តាប់ធ្នាប់សាធារណៈ និង មានមធ្យោបាយស្របច្បាប់ ក្នុងការប្រើប្រាស់កងកម្លាំងក្នុងគោលបំណងនោះ នៅពេលពួកគេកំពុងរងការវាយប្រហារ" ដែលដកស្រង់ *រឿងក្តី Kayishema* កថាខណ្ឌ ១២៧។

[46] Tsagourias ឯកសារ D191/9 កថាខណ្ឌ ១៧។

[47] *សូមមើល* Saul ឯកសារ D191/3 កថាខណ្ឌ ១៩។

[48] *សូមមើល* សារណា កថាខណ្ឌ ៦។

[49] គណៈប្រតិភូមួយចំនួនបានពិចារណាថា ឃ្លានេះត្រូវតែរក្សាទុក "ដើម្បីបញ្ចៀសការកែប្រែសំខាន់ៗទៅលើនិយមន័យដែលមានស្រាប់នៃឧក្រិដ្ឋកម្មទាំងនេះ" របាយការណ៍របស់គណៈកម្មាធិការរៀបចំស្តីពីការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ ភាគ ១ ឯកសារ អ.ស.ប. A/51/22 ឆ្នាំ ១៩៩៦ កថាខណ្ឌ ៨៦។ ទោះបីជាមានសំណើសុំឲ្យជំនួសពាក្យ "ការវាយប្រហារ" ដោយពាក្យ "អំពើ" ឬ "ឧក្រិដ្ឋកម្ម" ក៏ដោយ ក៏មានសំណើចំនួនតិចតួចប៉ុណ្ណោះ ដែលសុំឲ្យលុបពាក្យ "ជនស៊ីវិល" ឬ "ប្រជាជនស៊ីវិល" ពី

១២. Saul អះអាងថា ច្បាប់ IHL មិនអាចកំណត់អត្ថន័យនៃពាក្យ "ប្រជាជនស៊ីវិល" នៅក្រៅជម្លោះប្រដាប់អាវុធបានឡើយ[50] ហើយថា អត្ថន័យសាមញ្ញនៃពាក្យ "ប្រជាជនស៊ីវិល" គឺមិនច្បាស់លាស់។ គាត់ចង់បាននិយមន័យមួយដែលស្មើនឹង "អ្នករស់នៅក្នុងប្រទេស ឬ តំបន់មួយ"[51]។ Windridge អះអាងដោយគ្មានឯកសារសំអាងថា ពាក្យ "ប្រជាជនស៊ីវិល" អាចរាប់បញ្ចូលទាហាន ដូចដែលពាក្យនេះបានរាប់បញ្ចូលគ្រូបង្រៀន ឬ វេជ្ជបណ្ឌិតដូច្នេះដែរ[52]។ មិនសមហេតុផល។ Saul និង Windridge ព្យាយាមអនុវត្តនិយមន័យនៃពាក្យ "ប្រជាជន"[53] ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនមែនពាក្យប្រជាជន "ស៊ីវិល" ឡើយ។ អត្ថន័យសាមញ្ញនៃពាក្យ "ប្រជាជនស៊ីវិល" មានភាពច្បាស់លាស់ក្នុងពេលមានសន្តិភាព ឬ សង្គ្រាម។ ពាក្យនេះមានន័យថា ប្រជាជនមិនមែនយោធា[54]។

---

និយមន័យនេះ។ របាយការណ៍នៃគណៈកម្មាធិការរៀបចំស្តីពីការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ ភាគ ២ ឯកសារ អ.ស.ប. A/51/22 ឆ្នាំ ១៩៩៦ ទំព័រ ៦៥-៦៩។ លក្ខន្តិកៈតុលាការ ICC ស្របនឹងសាលាក្តី *មិនអចិន្ត្រៃយ៍* និង សាលាក្តីព្រហ្មទណ្ឌអន្តរជាតុបនីយកម្ម។ មាត្រា ៥ នៃលក្ខន្តិកៈសាលាក្តី ICTY។ មាត្រា ៣ នៃលក្ខន្តិកៈសាលាក្តី ICTR។ មាត្រា ២ នៃលក្ខន្តិកៈតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន។ រដ្ឋបាលអន្តរកាល អ.ស.ប. នៅប្រទេសទីម័រខាងកើត បទបញ្ញត្តិ ២០០០/១៥ ស្តីពីការបង្កើតក្រុមដែលមានយុត្តាធិការផ្តាច់មុខលើបទល្មើសព្រហ្មទណ្ឌធ្ងន់ធ្ងរ (Establishment of Panels with Exclusive Jurisdiction over Serious Offences) ផ្នែក ៥.១។

[50] Saul ឯកសារ D191/3 កថាខណ្ឌ ៧-១៥។ មេធាវីការពារក្តីជំទាស់ការអះអាងរបស់ Saul ដែលថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ និង អង្គជំនុំជម្រះសាលាដំបូងមានភាពត្រឹមត្រូវក្នុងសេចក្តីសម្រេចរបស់ខ្លួនស្តីពីលក្ខខណ្ឌតម្រូវនៃចំណងទាក់ទង។ *សូមមើល* បណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង ចំណងទាក់ទងជាមួយនឹងជម្លោះប្រដាប់អាវុធ ចុះថ្ងៃទី ១ ខែកក្កដា ឆ្នាំ ២០១៦ ឯកសារ D87/2/1.7/1/1/2។

[51] Saul ឯកសារ D191/3 កថាខណ្ឌ ១៦-១៩។

[52] Windridge ឯកសារ D191/10 កថាខណ្ឌ ១៦។

[53] វចនានុក្រម Merriam-Webster លើអ៊ិនធឺណែត ឲ្យនិយមន័យពាក្យ "ប្រជាជន" *ក្នុងចំណោមនោះ* ថាជា "ចំនួនប្រជាជនដែលរស់នៅក្នុងទីកន្លែងមួយ" ឬ "ចំនួនប្រជាជនទាំងអស់ ឬ អ្នករស់នៅក្នុងប្រទេស ឬ តំបន់មួយ"។ *សូមមើល* វចនានុក្រម Merriam-Webster *នៅលើគេហទំព័រ* http://www.merriam-webster.com/dictionary/population (ចូលពិនិត្យលើកចុងក្រោយនៅថ្ងៃទី ៦ ខែកក្កដា ឆ្នាំ ២០១៦)។

[54] ចំណុចនេះមានភាពស៊ីសង្វាក់ជាមួយនឹងនិយមន័យបែប "ចង្អៀត" នៃពាក្យ "ប្រជាជនស៊ីវិល" ដែល Saul ច្រានចោល។ *សូមមើល* Saul ឯកសារ D191/3 កថាខណ្ឌ ១៧។ និយមន័យនៃពាក្យ "ស៊ីវិល" ក្នុង*វចនានុក្រមវិទ្យាស្ថានបារាំង* (Dictionnaire de l'Académie française) ក៏បានដាក់បញ្ចូលផងដែរនូវនិយមន័យដែលបែងចែកខុសគ្នារវាងជនស៊ីវិល និង យោធា៖ "Par opposition à *Militaire. Les autorités civiles et militaires. Le courage civil. Une pension civile. Après avoir servi plusieurs années dans l'armée, il a obtenu un emploi civil. Être en tenue civile* et, ellipt., *être en civil.* Subst. *Un civil*...." ការបកប្រែក្រៅផ្លូវការ៖ *"ផ្ទុយនឹងយោធា។ អាជ្ញាធរស៊ីវិល និង យោធា។ សេចក្តីក្លាហានស៊ីវិល។ សោធននិវត្តន៍ជន*

បើទោះជាមានភាពមិនច្បាស់លាស់នៅក្នុងអត្ថន័យរបស់ពាក្យនេះក៏ដោយ ក៏យើងមិនអាចគ្រាន់តែជ្រើសរើសយកអត្ថន័យទូលំទូលាយជាងនេះឡើយ។ ត្រូវតែអនុវត្ត គោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ*[55]។

## ២. ច្បាប់ IHL មិនបានគាំទ្រការចាត់ទុកទាហានរបស់រដ្ឋជាប្រជាជនស៊ីវិលឡើយ

១៣. Trial អះអាងថា បទបញ្ញត្តិទីក្រុងឡាអេទទួលស្គាល់លទ្ធភាពដែលថា ទាហានអាចមិនត្រូវបានចាត់ទុកជាយុទ្ធជន[56]។ មិនពាក់ព័ន្ធ។ បញ្ញត្តិឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនតម្រូវឱ្យការវាយប្រហារត្រូវសំដៅទៅលើប្រជាជន *ដែលមិនមែនជាយុទ្ធជន* ឡើយ។ ការណ៍ដែលថាទាហានអាចត្រូវបានចាត់ទុកជាអ្នកមិនមែនជាយុទ្ធជន មិនស្មើគ្នាទៅនឹងការដែលចាត់ទុកពួកគេជាជនស៊ីវិលឡើយ។

១៤. Trial អះអាងថា ទាហានរបស់រដ្ឋមិនអាចជាគោលដៅឡើយ នៅពេលដែលពួកគេមិនបានចូលរួមដោយផ្ទាល់ក្នុងការប្រយុទ្ធប្រឆាំងនឹងរដ្ឋរបស់ខ្លួន ពីព្រោះក្នុងច្បាប់ IHL ជនស៊ីវិលមិនអាចជាគោលដៅឡើយ នៅពេលដែលពួកគេមិនបានចូលរួមដោយផ្ទាល់ក្នុងការប្រយុទ្ធនោះ[57]។ នាំឱ្យយល់ខុស។ ភាពសមហេតុផលនេះ គឺផ្អែកលើការជឿជាក់ដែលខុស និង ទឡ្ហីករណ៍ដែលមិនទាក់ទង។ បញ្ហាមិនមែនថា តើច្បាប់ IHL អនុញ្ញាតឱ្យកំណត់ទាហានដែលមិនចូលរួមដោយផ្ទាល់ក្នុងការប្រយុទ្ធជាគោលដៅឬយ៉ាងណានោះឡើយ ប៉ុន្តែគឺថា តើច្បាប់ ICL អនុញ្ញាតឱ្យចាត់ទុកទាហានជាប្រជាជនស៊ីវិលឬយ៉ាងណា។

១៥. Trial ក៏អះអាងផងដែរថា ជនស៊ីវិលជាជនដែលទទួលបានការការពារ នៅពេលត្រូវបានឃុំឃាំង លក្ខខណ្ឌតម្រូវផ្អែកសញ្ជាតិចំពោះជនទាំងនេះ អាចបកស្រាយឱ្យមានន័យថា ពួកគេអាចគ្រាន់តែមានភក្ដីភាពចំពោះរដ្ឋដែលមិនមែនជារដ្ឋដែលឃុំឃាំងពួកគេ ហើយហេតុដូច្នេះទាហានអាចទទួលបានការការពារក្នុងនាមជាជនស៊ីវិលត្រង់ចំណុចនេះ[58]។ នាំឱ្យយល់ខុស។ ភាពសមហេតុផលនេះ

---

*ស៊ីវិល។ ក្រោយពីបានបម្រើការងារជាច្រើនឆ្នាំ គាត់បានទទួលការងារស៊ីវិល។ នៅក្នុងសម្លៀកបំពាក់ស៊ីវិល និង លុបចោល* (ellipt.) *ជាស៊ីវិល។ នាម ជនស៊ីវិល...*"។

[55] *សូមមើល* សារណា កថាខណ្ឌ ២៥។

[56] Trial ឯកសារ D191/5 កថាខណ្ឌ ១២។

[57] *ដូចខាងលើ* កថាខណ្ឌ ១៤-១៥។

[58] *ដូចខាងលើ* កថាខណ្ឌ ១៤ កថាខណ្ឌ ១៦។

គឺផ្អែកលើការជឿជាក់ដែលខុស។ ច្បាប់ដែលគ្រប់គ្រងទៅលើថា តើជនស៊ីវិលអាចជាជនដែលទទួលបានការពារឬយ៉ាងណានោះ មិនបានដោះស្រាយបញ្ហាថា តើ *ទាហាន* អាចជាជនដែលទទួលបានការការពារឬយ៉ាងណាឡើយ។ យុត្តិសាស្ត្រសាលាក្តី ICTY ដែលដកស្រង់ បានពង្រីកអត្ថន័យនៃពាក្យ "ជនដែលទទួលបានការការពារ"។ យុត្តិសាស្ត្រនេះមិនឆ្លុះបញ្ចាំងអំពីច្បាប់ជាធរមានក្នុងឆ្នាំ ១៩៧៥-១៩៧៩ ឡើយ[59]។

១៦. Tsagourias អះអាងថា ច្បាប់ IHL បែងចែកខុសគ្នាតែរវាងជនស៊ីវិល និង យុទ្ធជនខ្មាំងប៉ុណ្ណោះ។ ទាហានដែលមិនមែនជាផ្នែកមួយនៃប្រជាជនខ្មាំង គឺជាជនស៊ីវិល[60]។ មិនត្រឹមត្រូវ។ ទាហានតែងតែខុសគ្នាពីជនស៊ីវិល[61]។ គោលការណ៍នៃភាពខុសគ្នាអាចបែងចែកទាហានខ្មាំងចេញពីជនស៊ីវិលសម្រាប់គោលបំណងនៃការកំណត់គោលដៅស្របច្បាប់ក្នុងច្បាប់ IHL។ ច្បាប់នេះមិនបានចែងថា តើទាហានអាចជាប្រជាជនស៊ីវិលក្នុងច្បាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឬយ៉ាងណាឡើយ។

១៧. Baltimore អះអាងថា មាត្រា ៣ រួម តម្រូវឲ្យមានការប្រព្រឹត្តបែបមនុស្សធម៌ចំពោះជនទាំងឡាយណាដែលបានទម្លាក់អាវុធ។ បើទោះជាទាហានរបស់រដ្ឋមិនមែនជាជនស៊ីវិលក៏ដោយ ក៏ពួកគេគួរតែទទួលបានការការពារក្នុងនាមជា *ទាហានគ្មានលទ្ធភាពប្រយុទ្ធ*[62]។ Trial អះអាងស្រដៀងនេះថា លើកលែងតែទាហានដើរតួជាសត្រូវចំពោះរដ្ឋរបស់ខ្លួន ពួកគេគួរត្រូវបានចាត់ទុកជា *ទាហានគ្មានលទ្ធភាពប្រយុទ្ធ* ចំពោះរដ្ឋនោះ[63]។ មិនសមហេតុសមផល។ ការណ៍ដែលថាទាហានរបស់រដ្ឋអាចទទួលបានការការពារតាមអនុសញ្ញាទីក្រុងហ្សឺណែវ មិនមែនចង្អុលបង្ហាញថា ពួកគេអាចជាប្រជាជនស៊ីវិលក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ។

## ៣. គ្មានការគាំទ្រដល់ការប្រើប្រាស់វិធីសាស្ត្រដែលផ្អែកលើគោលដៅស្របច្បាប់/មុខងារ

១៨. *អ្នកដែលមិនមែនជាភាគី* អះអាងថា ពាក្យ "ជនស៊ីវិល" ប្រើសម្រាប់គោលបំណងមុខងារក្នុងច្បាប់ IHL ដែលអាចឲ្យមានការបែងចែកផ្លូវច្បាប់រវាងគោលដៅស្របច្បាប់ និង មិនស្របច្បាប់

---

[59] *សូមមើល* ពាក្យសុំរបស់លោក មាស មុត ឲ្យប្តឹងទៅអង្គបុរេជំនុំជម្រះអំពីសំណើសុំមោឃភាពបទចោទប្រកាន់ពីអំពើរំលោភបំពានធ្ងន់ធ្ងរ ចុះថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ ២០១៥ ឯកសារ D146។

[60] Tsagourias ឯកសារ D191/9 កថាខណ្ឌ ២៣។

[61] *សូមមើល* ផ្នែក គ១ *ខាងលើ*។

[62] Balimore ឯកសារ D191/12 កថាខណ្ឌ ១០។

[63] Trial ឯកសារ D191/5 កថាខណ្ឌ ១៨-២០។

ក្នុងជម្លោះប្រដាប់អាវុធ ហើយថា ជនទាំងឡាយណាដែលមិនពាក់ព័ន្ធក្នុងជម្លោះ ឬ មិនមែនជាគោលដៅដោយសារហេតុផលដែលមិនទាក់ទងនឹងជម្លោះ គឺជាគោលដៅមិនស្របច្បាប់ ហើយត្រូវតែចាត់ទុកជាផ្នែកមួយនៃប្រជាជនស៊ីវិល[64]។ នាំឲ្យយល់ខុស។ គោលការណ៍នៃច្បាប់ IHL មិនអាចត្រូវបានបញ្ចូលទាំងស្រុងទៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ។ រដ្ឋអាចរំលោភច្បាប់ IHL តាមរយៈការវាយប្រហារគោលដៅដែលមិនស្របច្បាប់ ដោយមិនធ្វើការវាយប្រហារដែលពាក់ព័ន្ធនឹងការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គល។ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវតែប្រព្រឹត្តទៅលើប្រជាជនស៊ីវិល មិនមែនត្រឹមតែទៅលើគោលដៅមិនស្របច្បាប់ឡើយ។

១៩. Robinson និង អ្នកផ្សេងទៀត អះអាងថា យុត្តិសាស្ត្រគាំទ្រវិធីសាស្ត្រដែលផ្អែកលើគោលដៅស្របច្បាប់[65]។ មិនត្រឹមត្រូវ។ ពួកគេសំអាងលើយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរ ដែលពោលប្រាស្រ័យថា តើយុទ្ធជន ឬ ទាហានអាចជា *ជនរងគ្រោះ* នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឬយ៉ាងណា[66]។ រឿងក្តីទាំងនេះមិនបានវិភាគអត្ថន័យនៃពាក្យ "ប្រជាជនស៊ីវិល" ឡើយ។ ប៉ុន្តែ រឿងក្តីទាំងនេះបានសម្រេចថា *ជនរងគ្រោះ* នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិអាចជាទាហាន ដែលជាជំហរមួយច្រានចោលដោយតុលាការកំពូលពិសេសហូឡង់ (Dutch Special Court of Cassation) ក្នុងរឿងក្តី *Pilz*[67] និង តុលាការឧទ្ធរណ៍អង់គ្លេសប្រចាំនៅប្រទេសអាឡឺម៉ង់ក្នុងរឿងក្តី *Neddermeier*[68]។ Robinson និង អ្នកផ្សេងទៀត អះអាងថា ស្ថាប័នអន្តរជាតិបានអនុវត្តតាមវិធីសាស្ត្រដែលផ្អែកលើគោលដៅស្របច្បាប់នេះ ដោយដកស្រង់ត្រឹមតែសំដីរបស់គណៈកម្មការអ្នកជំនាញ ស្តីពីអតីតប្រទេសយូហ្គោស្លាវីប៉ុណ្ណោះ[69]។ គណៈកម្មការនេះមិនបានទទួលយកវិធីសាស្ត្រ

---

[64] *ដូចខាងលើ* កថាខណ្ឌ ១៤-១៥។ Robinson, deGuzman, Jalloh និង Cryer ចុះថ្ងៃទី ១៧ ខែឧសភា ឆ្នាំ ២០១៦ ឯកសារ D191/6 ("Robinson និង អ្នកផ្សេងទៀត ឯកសារ D191/6") កថាខណ្ឌ ៩-២១។ Rosenzweig ឯកសារ D191/7 ទំព័រ ៥ កថាខណ្ឌ ៣ ទំព័រ ៤ កថាខណ្ឌ ១។ Williams & Grey ឯកសារ D191/11 កថាខណ្ឌ ៦ កថាខណ្ឌ ១៦-១៧។ Baltimore ឯកសារ D191/12 កថាខណ្ឌ ៤-៥។

[65] Robinson និង អ្នកផ្សេងទៀត ឯកសារ D191/6 កថាខណ្ឌ ៩-២១។

[66] *សូមមើល* ផ្នែក ច *ខាងក្រោម* ដែលពន្យល់អំពីហេតុផលដែលធ្វើឲ្យបញ្ហានេះមានភាពខុសគ្នា មិនជាប់ទាក់ទង និង ដែលពិភាក្សាអំពីរឿងក្តីថ្នាក់ជាតិ។

[67] រឿងក្តី *In re Pilz* តុលាការកំពូលពិសេស ចុះថ្ងៃទី ៥ ខែកក្កដា ឆ្នាំ ១៩៥០។

[68] យោងតាមសេចក្តីសង្ខេបក្នុង Emily Haslam, *Neddermeier ក្នុង* ANTONIO CASSESE និង អ្នកផ្សេងទៀត ដៃគូ Oxford ទៅនឹងយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ (The Oxford Companion to International Criminal Justice) ៨៤០ (សារព័ត៌មានសកលវិទ្យាល័យ Oxford ឆ្នាំ ២០០៩)។

[69] Robinson ឯកសារ D191/6 កថាខណ្ឌ ១៤។

ដែលផ្អែកលើគោលដៅស្របច្បាប់ឡើយ។ គណៈកម្មការនេះបានថ្លែងថា៖ "ពាក្យ 'ប្រជាជនស៊ីវិល' ត្រូវបានប្រើប្រាស់ក្នុងបរិបទនេះ ដើម្បីបង្ហាញឲ្យឃើញភាពខុសគ្នាពីយុទ្ធជន *ឬ សមាជិកនៃកងកម្លាំងប្រដាប់អាវុធ*"[70]។ ប្រសិនបើមានចេតនាប្រើវិធីសាស្ត្រដែលផ្អែកលើគោលដៅស្របច្បាប់មែននោះ គណៈកម្មការនេះនឹងប្រៀបធៀបភាពខុសគ្នានៃពាក្យ "ប្រជាជនស៊ីវិល" តែជាមួយនឹងយុទ្ធជនទៅហើយ ជាជាងប្រើប្រាស់និយមន័យសាមញ្ញរបស់ពាក្យនេះ។

២០. Robinson និង អ្នកផ្សេងទៀត អះអាងថា សាលាក្តី *មិនអចិន្ត្រៃយ៍* បានដកចេញដោយមិនសមហេតុផលពីវិធីសាស្ត្រដែលផ្អែកលើគោលដៅស្របច្បាប់នេះ[71]។ មិនត្រឹមត្រូវ។ អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Akayesu* អាចឲ្យនិយមន័យពាក្យ "ប្រជាជនស៊ីវិល" តាមបែបទូលាយ[72]។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះមិនបានប្រឈមជាមួយនឹងបញ្ហាថាតើទាហានរបស់រដ្ឋអាចក្លាយជាប្រជាជនស៊ីវិល ឬ ក៏និយមន័យរបស់ខ្លួនត្រូវបានពិចារណានៅក្នុងបណ្តឹងឧទ្ធរណ៍ឬយ៉ាងណាឡើយ។ រឿងក្តី *Tadić* និង យុត្តិសាស្ត្រផ្សេងទៀត មិនបានកំណត់ថា ទាហានអាចជាប្រជាជនស៊ីវិលឡើយ ប៉ុន្តែថា ពួកគេអាចជា *ជនរងគ្រោះ*[73] ឬ ថា *ទាហានដែលគ្មានលទ្ធភាពប្រយុទ្ធ* អាចជាប្រជាជនស៊ីវិល[74]។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា *ទាហានដែលគ្មានលទ្ធភាពប្រយុទ្ធ មិន* អាចជាប្រជាជនស៊ីវិលឡើយ[75]។ អង្គជំនុំជម្រះមិនបាន "ចម្លង" និយមន័យរបស់

---

[70] របាយការណ៍ចុងក្រោយនៃគណៈកម្មការអ្នកជំនាញ ដែលត្រូវបានបង្កើតឡើង អនុលោមតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខ ៧៨០ (ឆ្នាំ ១៩៩២) ឯកសារ អ.ស.ប S/1994/674 ឧបសម្ព័ន្ធ (ឆ្នាំ ១៩៩៤) កថាខណ្ឌ ៧៧ (គូសបញ្ជាក់បន្ថែម)។

[71] Robinson និង អ្នកផ្សេងទៀត ឯកសារ D191/6 កថាខណ្ឌ ១៨-២១។

[72] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* *Akeyesu* សំណុំរឿងលេខ ICTR-96-4-T សាលក្រម ចុះថ្ងៃទី ១ ខែមិថុនា ឆ្នាំ ២០០១ កថាខណ្ឌ ៥៨២ ដែលឲ្យនិយមន័យពាក្យ "ប្រជាជនស៊ីវិល" ថាជា "មនុស្សដែលមិនបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធ រួមទាំងសមាជិកនៃកងកម្លាំងប្រដាប់អាវុធ ដែលបានទម្លាក់អាវុធ និង ជនទាំងឡាយណាដែល *គ្មានលទ្ធភាពប្រយុទ្ធ* ដោយសារជំងឺ របួស ការឃុំឃាំង ឬ មូលហេតុផ្សេងទៀត"។

[73] ទាក់ទងនឹងរឿងក្តី *Tadić* *សូមមើល* រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* *Tadić* សំណុំរឿងលេខ IT-94-1-T សាលក្រម ចុះថ្ងៃទី ៧ ខែឧសភា ឆ្នាំ ១៩៩៧ កថាខណ្ឌ ៦៤៣ (គូសបញ្ជាក់បន្ថែម)៖ "ទោះបីជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ *ត្រូវតែមានគោលដៅសំដៅលើប្រជាជនស៊ីវិល* ក៏ដោយ ក៏បុគ្គលដែលនៅពេលមួយនោះបានធ្វើសកម្មភាពតវ៉ា អាចក្នុងកាលៈទេសៈមួយចំនួនជា *ជនរងគ្រោះ* នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"។

[74] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* *Jelisić* សំណុំរឿងលេខ IT-95-10-T សាលក្រម ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ ១៩៩៩ កថាខណ្ឌ ៥៤។

[75] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* *Blaškić* សំណុំរឿងលេខ IT-95-14-A សាលក្រម ចុះថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ ២០០៤ កថាខណ្ឌ ១០៣-១១៦។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* *Galić* សំណុំរឿងលេខ IT-98-29-A សាលក្រម ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០០៦ កថាខណ្ឌ ១៤៤។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* *Martić* សំណុំរឿងលេខ IT-95-11-A សាលក្រម ចុះថ្ងៃទី ៨ ខែតុលា ឆ្នាំ

ពិធីសារបន្ថែម I នៃពាក្យ "ជនស៊ីវិល" ឡើយ[76]។ អង្គជំនុំជម្រះបានដឹងអំពីកាតព្វកិច្ចរបស់ខ្លួនក្នុងការពិនិត្យបញ្ជាក់ឲ្យច្បាស់អំពីច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលអាចអនុវត្តបាន[77]។ អង្គជំនុំជម្រះបានពិចារណា *ក្នុងចំណោមនោះ* លើសេចក្តីអធិប្បាយរបស់ ICRC[78] ដែលបានទទួលស្គាល់ដោយតណ្ហីភាពនូវភាពខុសគ្នារវាងជនស៊ីវិល និង ទាហាន៖ "ជនស៊ីវិលណាដែលត្រូវបានបញ្ចូលទៅក្នុងអង្គការប្រដាប់អាវុធ ... ក្លាយជាសមាជិកយោធា ..."[79]។

២១. Williams និង Grey អះអាងថា ការពង្រីកវិសាលភាពនៃការការពារពីច្បាប់ IHL ដោយអង្គជំនុំជម្រះសាលាដំបូង ក្នុងរឿងក្តី *Prlić* ទៅដល់ទាហានដែលត្រូវបានឃុំឃាំងដោយកងកម្លាំងរបស់ខ្លួន គឺស៊ីសង្វាក់ជាមួយនឹងវិធីសាស្ត្រដែលផ្អែកលើមុខងារ ដែលកំណត់និយមន័យនៃពាក្យ "ជនស៊ីវិល"[80]។ នាំឲ្យយល់ខុស។ អង្គជំនុំជម្រះសាលាដំបូងអាចបានពង្រីកវិសាលភាពនៃការការពារពីច្បាប់ IHL ទៅដល់អ្នកជាប់ឃុំទាំងនេះ។ ទោះជាដូច្នេះក្តី អង្គជំនុំជម្រះបានសម្រេចថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានតម្រូវឲ្យមានការវាយប្រហារសំដៅលើប្រជាជន *ស៊ីវិល*[81]។ រឿងក្តី *Prlić* មិនបានគាំទ្រការអះអាងដែលថា ទាហានដែលក្លាយជាគោលដៅដោយសារតែភក្តីភាពរបស់ពួកគេត្រូវបានយល់ថាមានចំពោះបក្សមួយទៀត គួរត្រូវបានចាត់ទុកជាប្រជាជនស៊ីវិលនោះឡើយ។

---

២០០៨ កថាខណ្ឌ ២៩១-៣១៤។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Mrkšić* សំណុំរឿងលេខ IT-95-13/1-A សាលក្រម ចុះថ្ងៃទី ៥ ខែឧសភា ឆ្នាំ ២០០៩ កថាខណ្ឌ ២០-៣៣។

[76] ដូចដែលលើកឡើងនៅក្នុង Robinson និង អ្នកផ្សេងទៀត ឯកសារ D191/6 កថាខណ្ឌ ១៨។

[77] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Blaškić* សំណុំរឿងលេខ IT-95-14-A សាលក្រម ចុះថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ ២០០៤ កថាខណ្ឌ ១១០។

[78] *ដូចខាងលើ* កថាខណ្ឌ ១១៤។

[79] ដូចដែលដកស្រង់ *ដូចខាងលើ*។

[80] Williams & Grey ឯកសារ D191/11 កថាខណ្ឌ ១០-១៥។

[81] *សូមមើល* សារណា កថាខណ្ឌ ១៣ កថាខណ្ឌ ២២ ដែលពិភាក្សាអំពីសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Prlić*។ "តេស្តភក្តីភាព" ដែលសំអាងដោយអង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Prlić* មិនមែនជាផ្នែកមួយនៃច្បាប់ជាធរមានក្នុងឆ្នាំ ១៩៧៥-១៩៧៩ ឡើយ។ *សូមមើល* កថាខណ្ឌ ១៥ *ខាងលើ*។

## ឃ. ច្បាប់សិទ្ធិមនុស្សអន្តរជាតិ ("ច្បាប់ IHRL") មិនអាចកែប្រែអត្ថន័យនៃពាក្យ "ប្រជាជនស៊ីវិល" បានឡើយ

២២. *អ្នកដែលមិនមែនជាភាគី* អះអាងថា ច្បាប់ IHRL គាំទ្រការបកស្រាយពាក្យ "ប្រជាជនស៊ីវិល" ដោយរាប់បញ្ចូលទាំងទាហានរបស់រដ្ឋ[82]។ មិនសមហេតុផល។ ច្បាប់ IHRL ខុសពីច្បាប់ ICL។ ស្ថាប័នច្បាប់ដែលដាច់ដោយឡែកពីគ្នានេះ មិនអាចបញ្ចូលគ្នាបានឡើយ[83]។ ទឡ្ហីករណ៍របស់ TRIAL[84] ដែលថា ច្បាប់ IHRL ជា *ច្បាប់ពិសេស* (lex specialis) នៃច្បាប់ IHL ស្រដៀងគ្នានេះដែរគឺមិនសមហេតុផល ព្រមទាំងមិនត្រឹមត្រូវ[85]។ ច្បាប់ IHRL ជាទូទៅដាក់កាតព្វកិច្ចទៅលើរដ្ឋ។ ច្បាប់ ICL ដាក់ការទទួលខុសត្រូវទៅលើបុគ្គល។ អនុសញ្ញា IHRL (ឧទាហរណ៍ កតិកាសញ្ញា ICCPR សេចក្តីប្រកាស UDHR និង អនុសញ្ញាប្រឆាំងនឹងទារុណកម្ម) មិនកំណត់ថាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាបទល្មើសព្រហ្មទណ្ឌឡើយ[86]។ ពួកគេមិនអាចពង្រីកវិសាលភាពនៃបញ្ញត្តិព្រហ្មទណ្ឌ ឬ ច្បាប់ ICL ទំនៀមទម្លាប់ឡើយ។ ការពង្រីកវិសាលភាពបែបប្រតិសកម្មនៃបញ្ញត្តិព្រហ្មទណ្ឌ ដើម្បីគ្របដណ្តប់លើការរំលោភច្បាប់ IHRL គឺផ្ទុយពីគោលការណ៍ *គ្មានបទ*

---

[82] TRIAL ឯកសារ D191/5 កថាខណ្ឌ ១-១០។ Williams & Grey ឯកសារ D191/11 កថាខណ្ឌ ២០។ Baltimore ឯកសារ D191/12 កថាខណ្ឌ ១២-១៦។

[83] *សូមមើល* រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Kunarac* សំណុំរឿងលេខ IT-96-23-T & IT-96-23/1-T សាលក្រម ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ ២០០១ កថាខណ្ឌ ៤៦៨-៤៧១ ដែលបានពន្យល់ថា នៅពេលកំណត់អំពីនិយមន័យតាមទំនៀមទម្លាប់នៃពាក្យទារុណកម្ម វាមិនអាចគ្រាន់តែទទួលយកនិយមន័យនេះតាមច្បាប់ IHRL ឡើយ ដោយសារតែមានភាពខុសគ្នានៃរចនាសម្ព័ន្ធក្នុងស្ថាប័នច្បាប់ដែលខុសគ្នា។ អង្គជំនុំជម្រះសាលាដំបូងចាំបាច់ត្រូវពិចារណា *ក្នុងចំណោមនោះ* ជាតួនាទី និង ឋានៈរបស់រដ្ឋនោះក្នុងនាមជាអ្នកប្រព្រឹត្ត គឺខុសគ្នាក្នុងច្បាប់ IHRL និង ច្បាប់ IHL។ *ដូចខាងលើ* កថាខណ្ឌ ៤៧០(ii)។

[84] Trial ឯកសារ D191/5 កថាខណ្ឌ ៧។

[85] *សូមមើល នីត្យានុកូលភាពនៃការគំរាម ឬ ការប្រើប្រាស់អាវុធនុយក្លេអ៊ែរ យោបល់ប្រឹក្សា* របាយការណ៍ I.C.J ឆ្នាំ ១៩៩៦ កថាខណ្ឌ ២៥ ដែលតុលាការយុត្តិធម៌អន្តរជាតិសង្កេតឃើញថា ទោះជាការការពារតាមកតិកាសញ្ញា ICCPR មិនត្រូវផ្អាកនៅក្នុងពេលមានសង្គ្រាមក៏ដោយ ក៏*ច្បាប់ពិសេស* (lex specialis) ដែលអាចអនុវត្តបានក្នុងពេលមានសង្គ្រាម គឺច្បាប់ IHL។ Trial បកស្រាយខុសនូវរបាយការណ៍នៃក្រុមសិក្សារបស់គណៈកម្មការនីតិអន្តរជាតិ ការបែងចែកជាផ្នែកនៃច្បាប់អន្តរជាតិ ឯកសារ អ.ស.ប. A/CN.4/L.682 ចុះថ្ងៃទី ១៣ ខែមេសា ឆ្នាំ ២០០៦ កថាខណ្ឌ ៥៧ (Trial ឯកសារ D191/5 ជើងទំព័រ ១៥) និង ខកខានមិនបានបង្ហាញឱ្យឃើញថា តើច្បាប់ IHRL និង ច្បាប់ ICL ផ្តល់ការណែនាំមិនស៊ីគ្នាអំពីរបៀបដែលត្រូវដោះស្រាយចំពោះអំពើរបស់រដ្ឋប្រឆាំងនឹងទាហានរបស់ខ្លួនឬយ៉ាងណា។

[86] *សូមមើល ឧទាហរណ៍* មាត្រា ៤-៥ នៃអនុសញ្ញាប្រឆាំងនឹងទារុណកម្ម ដែលតម្រូវឱ្យរដ្ឋចាត់វិធានការណ៍បង្កើតយុត្តាធិការ និង ផ្តន្ទាទោសចំពោះទារុណកម្មក្នុងនាមជាការរំលោភច្បាប់ព្រហ្មទណ្ឌ ប៉ុន្តែមិនបានចែងអំពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលឡើយ។

*ល្មើស បើគ្មានច្បាប់ចែង*[87]។ ការណ៍ដែលជនទាំងអស់អាចស្ថិតក្រោមការការពាររបស់ច្បាប់ IHRL ដូចៗគ្នា មិនមែនមានន័យថា ការវាយប្រហារទៅលើទាហានអាចជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងច្បាប់ ICL ឡើយ។ មិនមែនគ្រប់ការរំលោភច្បាប់ IHRL ជាការរំលោភច្បាប់ ICL ឡើយ[88]។

## ង. ការធ្វើទុក្ខបុកម្នេញមិនអាចត្រូវបានចាត់ទុកថា ខុសពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀតឡើយ

២៣. *អ្នកដែលមិនមែនជាភាគី* អះអាងថា ការធ្វើទុក្ខបុកម្នេញខុសពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀត ត្រង់ថា វាមិនតម្រូវឲ្យមានការវាយប្រហារទៅលើប្រជាជនស៊ីវិល[89]។ មិនត្រឹមត្រូវ។ គំនិតនេះផុសឡើងដោយសាររចនាសម្ព័ន្ធនៃមាត្រា ៦(គ) ក្នុងធម្មនុញ្ញ IMT ដែលបានបំបែកការធ្វើទុក្ខបុកម្នេញចេញពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀត ដោយប្រើសញ្ញាចុចក្បៀស និង ពាក្យនិបាត "ឬ"[90]។ ទោះបីជាបានកត់សម្គាល់អំពីការបែងចែកដាច់ដោយឡែកនេះក៏ដោយ ក៏អង្គជំនុំ

---

[87] *សូមមើល* មាត្រា ១៥ នៃកតិកាសញ្ញា ICCPR។

[88] "ស្ទើរតែគ្រប់ឧក្រិដ្ឋកម្មអន្តរជាតិ គឺជាការរំលោភសិទ្ធិមនុស្សជាមូលដ្ឋាន ប៉ុន្តែមិនមែនគ្រប់ការរំលោភសិទ្ធិមនុស្ស បណ្តាលឲ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌដោយផ្ទាល់ឡើយ។ ហេតុផលគឺថា សិទ្ធិមនុស្សបង្កើតកាតព្វកិច្ចជាចម្បងចំពោះរដ្ឋ ហើយវាអាស្រ័យលើរដ្ឋក្នុងការសម្រេចពីរបៀបដែលធានាឲ្យមានការគោរពកាតព្វកិច្ចទាំងនេះពីសំណាក់ភ្នាក់ងាររបស់ខ្លួន"។ Salif Nimaga *របបនីតិព្រហ្មទណ្ឌអន្តរជាតិ និង នីតិសិទ្ធិមនុស្សអន្តរជាតិ៖ ការស្វែងយល់ទ្រឹស្តី និង ការអនុវត្តជាក់ស្តែងក្នុង* សីលធម៌ និង សិទ្ធិមនុស្សនៅក្នុងពិភពសកលភាវូបនីយកម្ម ( The International Criminal Law Regime and International Human Rights Law: Theoretical and Empirical Explorations, Ethics and Human Rights in a Globalized World) ១០៤-១០៥ (ឆ្នាំ ២០០៩)។

[89] Drummond និង អ្នកផ្សេងទៀត ឯកសារ D191/4 កថាខណ្ឌ ១(ក)(ii) កថាខណ្ឌ ១១-១៧។ QUB ឯកសារ D191/13 កថាខណ្ឌ ៣-៩។

[90] បញ្ញត្តិនេះត្រូវបានកំណត់ស្រដៀងគ្នាក្នុងធម្មនុញ្ញសាលាក្តីយោធាអន្តរជាតិសម្រាប់ចុងបូព៌ា ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង និង គោលការណ៍ Nuremberg។ Schwelb បានពន្យល់ថា នៅក្នុងពិធីសារបែរឡាំង រដ្ឋបានជំនួសសញ្ញាចុចក្បៀសដោយសញ្ញាចុល្លភាគ ដើម្បីឲ្យសំណៅជាភាសាអង់គ្លេស និង បារាំងនៃធម្មនុញ្ញ IMT ស្របជាមួយនឹងសំណៅជាភាសារុស្ស៊ី។ ការជំនួសនេះពង្រីកវិសាលភាពលក្ខខណ្ឌតម្រូវនៃចំណងទាក់ទងទៅដល់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាំងអស់ ជាជាងតែលើឧក្រិដ្ឋកម្ម "ប្រភេទធ្វើទុក្ខបុកម្នេញ" និង បានធ្វើការបែងចែកឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាឧក្រិដ្ឋកម្មប្រភេទមនុស្សឃាត និង ឧក្រិដ្ឋកម្មប្រភេទធ្វើទុក្ខបុកម្នេញ ដែលមិនមាននិរន្តភាព។ Egon Schwelb *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ* ២៣ Brit. Y.B. Int'l L. ១៧៨, ១៩០, ១៩៤-១៩៥ (ឆ្នាំ ១៩៤៦)។ *សូមមើលផងដែរ* គណៈកម្មការនីតិអន្តរជាតិ អនុស្សរណៈនៃអគ្គលេខាធិការ អ.ស.ប. ធម្មនុញ្ញ និង សាលក្រមសាលាក្តី Nuremberg៖ ប្រវត្តិ និង ការវិភាគ ឯកសារ អ.ស.ប. A/CN.4/5 ឆ្នាំ ១៩៤៩ ទំព័រ ៦៥-៦៦។

ជម្រះតុលាការកំពូលនៃ អ.វ.ត.ក. មិនបានសន្និដ្ឋាន[91] ថា និយមន័យតាមទំនៀមទម្លាប់ជាធរមាន នៃការធ្វើទុក្ខបុកម្នេញ មានធាតុផ្សំ *ខុសប្លែក* ខុសពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀតនោះដែរ[92]។

២៤. គ្មានភស្តុតាងដែលបង្ហាញថា អ្នកព្រាងមាត្រា ៦(គ) មានបំណងឲ្យការធ្វើទុក្ខបុកម្នេញមានលក្ខខណ្ឌតម្រូវ *ខុសប្លែក* ខុសពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀតនោះឡើយ។ ការធ្វើដូច្នេះនឹងបណ្តាលឲ្យមានលទ្ធផលដែលមិនអាចទទួលយកបាន។ ប្រសិនបើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិអនុវត្តចំពោះតែប្រជាជនស៊ីវិល ក្នុងករណីដែលមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការនិរទេស ឬ អំពើអមនុស្សធម៌ផ្សេងទៀតបានកើតឡើង ប៉ុន្តែ ចំពោះប្រជាជន *ណា* ដែលការធ្វើទុក្ខបុកម្នេញបានកើតឡើងនោះ មនុស្សនឹងកាន់តែតិចដែលទទួលបានការការពារពីឧក្រិដ្ឋកម្មធ្ងន់ធ្ងរ (ឧទាហរណ៍ ការសម្លាប់រង្គាល) ជាងមនុស្សដែលទទួលបានការការពារពីឧក្រិដ្ឋកម្មមិនសូវធ្ងន់ធ្ងរ (ការធ្វើទុក្ខបុកម្នេញ)[93]។ Drummond និង អ្នកផ្សេងទៀត និង QUB ដកស្រង់អនុសញ្ញាអន្តរជាតិ យុត្តិសាស្ត្រសាលាក្តី ICTY និង យុត្តិសាស្ត្រតុលាការក្នុងស្រុក[94]។ មិនពាក់ព័ន្ធ។ អនុសញ្ញាស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និង អនុសញ្ញាស្តីពីអាប៉ាថេត ជាអនុសញ្ញាពិសេស។ អនុសញ្ញាទាំងនេះមិនបានកែប្រែនិយមន័យតាមទំនៀមទម្លាប់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ[95]។ យុត្តិសាស្ត្រនេះគ្រាន់តែចង្អុលបង្ហាញថា ទាហានអាចជា *ជនរងគ្រោះ* នៃការធ្វើទុក្ខបុកម្នេញប៉ុណ្ណោះ មិនមែនថា ទាហានអាចជា "ប្រជាជនស៊ីវិល" ទាក់ទងនឹងការធ្វើទុក្ខបុកម្នេញឡើយ[96]។

---

[91] ដូចដែលបានអះអាងដោយតណ្លីភាពដោយ Drummond និងអ្នកផ្សេងទៀត ឯកសារ D191/4 កថាខណ្ឌ ១៤។

[92] *រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សាលដីកា ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១២ ឯកសារ F28 ("សាលដីកា *ឌុច*") កថាខណ្ឌ ២៣៣។

[93] Egon Schwelb *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ* ២៣ Brit. Y.B. Int'l L. ១៧៨ ១៩០ (ឆ្នាំ ១៩៤៦)។ Drummond និង អ្នកផ្សេងទៀត កត់សម្គាល់ការចង្អុលបង្ហាញរបស់គណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាម អ.ស.ប. ដែលថា ការធ្វើទុក្ខបុកម្នេញតម្រូវឲ្យធ្វើទៅលើប្រជាជនស៊ីវិល។ Drummond និង អ្នកផ្សេងទៀត ឯកសារ D191/4 កថាខណ្ឌ ១៣។

[94] Drummond និង អ្នកផ្សេងទៀត ឯកសារ D191/4 កថាខណ្ឌ ១២-១៣។ QUB ឯកសារ D191/13 កថាខណ្ឌ ៣-៨។

[95] *សូមមើល* Drummond និង អ្នកផ្សេងទៀត ឯកសារ D191/4 កថាខណ្ឌ ១២ ដែលអះអាងថា អនុសញ្ញាទាំងនេះមិនតម្រូវឲ្យការធ្វើទុក្ខបុកម្នេញត្រូវប្រព្រឹត្តិទៅលើប្រជាជនស៊ីវិលឡើយ។

[96] *សូមមើល* ផ្នែក ច *ខាងក្រោម*។ QUB (ឯកសារ D191/13 កថាខណ្ឌ ៧) ក៏ដកស្រង់ផងដែរនូវសេចក្តីសម្រេចពីសន្និសីទឆ្នាំ ១៩៤៧ ស្តីពីឯកភាពវប្បនីយកម្មនៃនីតិព្រហ្មទណ្ឌ។ សេចក្តីសម្រេចនេះដែលព្រាងដោយអ្នកស្រាវជ្រាវ និង ដែលរដ្ឋមិនទទួល

២៥. មាត្រា ៥ នៃ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. តម្រូវឱ្យការវាយប្រហារទៅលើប្រជាជនស៊ីវិលជាធាតុផ្សំ *ទូទៅ* នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*ទាំងអស់*[97]។ Drummond និង អ្នកផ្សេងទៀត អះអាងថា ដោយហេតុថា "ទំនងជាគ្មានយុត្តិកម្មចំពោះ ឬ ចេតនាជាក់លាក់ក្នុងការដកចេញ" នូវការធ្វើទុក្ខបុកម្នេញទៅលើទាហានរបស់ប្រទេសកម្ពុជាពីយុត្តាធិការ អ.វ.ត.ក. មាត្រា ៥ អាចជា "ការប៉ុនប៉ងប្រតិសកម្ម និង ដែលមិនអាចអនុញ្ញាតឱ្យបាន ក្នុងការកែប្រែនិយមន័យតាម [ទំនៀមទម្លាប់] នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"[98]។ មិនត្រឹមត្រូវ។ រដ្ឋាភិបាលកម្ពុជាបានយល់ព្រមកំណត់និយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចដែលបានកំណត់ក្នុងលក្ខន្តិកៈតុលាការ ICC[99] ដែលដាក់បញ្ចូលច្បាប់ទំនៀមទម្លាប់អន្តរជាតិ[100]។ សូម្បីតែសន្មតថាមានភាពខុសគ្នារវាងការធ្វើទុក្ខបុកម្នេញ និង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀត ក៏ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. មិនទទួលស្គាល់ដែរ ហើយច្បាប់ទំនៀមទម្លាប់អន្តរជាតិក៏មិនបានទទួលស្គាល់ដែរ។ ក្នុងករណីដែលច្បាប់ចងកាតព្វកិច្ច ត្រូវបានកែប្រែនៅពេលបន្តបន្ទាប់ ទៅជាច្បាប់ដែលមានការអនុគ្រោះជាងច្បាប់ដែលចងកាតព្វកិច្ចតុលាការ ច្បាប់ដែលមានលក្ខណៈធូរស្រាលជាងនឹងត្រូវបានអនុវត្ត[101]។

### ច. ថាតើទាហាន រួមទាំង *អ្នកដែលគ្មានលទ្ធភាពប្រយុទ្ធ* អាចជាជនរងគ្រោះឬយ៉ាងណានោះ មិនមែនជាបញ្ហាឡើយ ហើយមិនមែនជាការកំណត់ថា តើទាហានអាចជាប្រជាជនស៊ីវិលឬយ៉ាងណាឡើយ

២៦. *អ្នកដែលមិនមែនភាគី* អះអាងថា យុត្តិសាស្ត្រដែលសម្រេចថា ទាហានអាចជាជនរងគ្រោះបង្ហាញឱ្យឃើញថា ទាហានអាចជាប្រជាជនស៊ីវិល[102]។ មិនត្រឹមត្រូវ។ យុត្តិសាស្ត្រដែលបង្ហាញឱ្យ

---

យក បានស្មើនិយមន័យមនុស្សឃាត។ វាមិនទាក់ទងទៅនឹងថា តើការធ្វើទុក្ខបុកម្នេញតម្រូវឱ្យមានការវាយប្រហារទៅលើប្រជាជនស៊ីវិលឬយ៉ាងណាឡើយ។

[97] ដូចដែលទទួលស្គាល់ដោយ QUB ឯកសារ D191/13 កថាខណ្ឌ ៩។

[98] Drummond និង អ្នកផ្សេងទៀត ឯកសារ D191/4 កថាខណ្ឌ ១៥-១៦។

[99] មាត្រា ៩ នៃកិច្ចព្រមព្រៀង។

[100] *សូមមើល* ជើងទំព័រ ៤៩ *ខាងលើ*។

[101] មាត្រា ១៥ នៃកតិកាសញ្ញា ICCPR។ *សូមមើលផងដែរ* រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Deronjic* សំណុំរឿងលេខ IT-02-61-A សាលក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០០៥ កថាខណ្ឌ ៩៧។

[102] Saul ឯកសារ D191/3 កថាខណ្ឌ ៤-៦។ Trial ឯកសារ D191/5 កថាខណ្ឌ ១៨-២០។ Tsagourias ឯកសារ D191/9 កថាខណ្ឌ ២៩។ Windridge ឯកសារ D191/10 កថាខណ្ឌ ៩ កថាខណ្ឌ ១៩។ Williams & Grey ឯកសារ D191/11 កថាខណ្ឌ ៣ ២៥-២៧ ២៩។ Baltimore ឯកសារ D191/12 កថាខណ្ឌ ១០។ QUB ឯកសារ D191/13 កថាខណ្ឌ ១២-១៥។

ឃើញថា ទាហានអាចជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនបានបង្ហាញឲ្យឃើញថា ទាហានអាចជាប្រជាជនស៊ីវិលឡើយ។ *អ្នកដែលមិនមែនភាគី* ផ្សេងទៀត បានទទួលស្គាល់យ៉ាងត្រឹមត្រូវថា ខណៈដែលទាហានអាចជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នេះជាបញ្ហាផ្សេងមួយទៀត និង មិនមែនជាកត្តាកំណត់ថា តើទាហានអាចជាប្រជាជនស៊ីវិលឬយ៉ាងណាឡើយ[103]។ តុលាការកំពូលនៅតំបន់ដែលកាន់កាប់ដោយប្រទេសអង់គ្លេស ដែលដកស្រង់ដោយ *អ្នកដែលមិនមែនភាគី* មួយចំនួន[104] មិនបានវិភាគអំពីអត្ថន័យនៃពាក្យ "ប្រជាជនស៊ីវិល" ឡើយ ប៉ុន្តែគ្រាន់តែវិភាគថា តើទាហានអាចជា *ជនរងគ្រោះ* នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឬយ៉ាងណា។ រឿងក្តីទាំងនេះ គឺមិនសមហេតុផល។ ក្នុងរឿងក្តី *R* និង *H* ចៅក្រម *មិន* បានពោលប្រាស្រ័យថា តើអំពើដែលជាបញ្ហាចោទបានកើតឡើង *ជាផ្នែកនៃការវាយប្រហារសំដៅលើប្រជាជនស៊ីវិលឬយ៉ាងណា* ឡើយ។ រឿងក្តីទាំងនេះផ្តោតលើ *ធាតុផ្សំអត្តនោម័ត* (mens rea)[105] និង ប្រព័ន្ធ Nazi[106]។ ក្នុងរឿងក្តី *P និង អ្នកផ្សេងទៀត* ចៅក្រមបានសម្រេចយ៉ាងច្បាស់លាស់ថា អំពើទាំងនេះមិនមែនជាអំពើប្រឆាំងនឹងប្រជាជនស៊ីវិល តាមច្បាប់លេខ ១០ នៃក្រុមប្រឹក្សាគ្រប់គ្រងនោះទេ[107] ប៉ុន្តែ ទោះជាដូច្នេះក្តី បានថ្លែងនៅក្នុង *សេចក្តីថ្លែងអំពីទស្សនៈ* (dictum) ថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានប្រព្រឹត្ត ដោយចង្អុលទៅបទល្មើសជាមូលដ្ឋានដែលចែងក្នុង

---

[103] Drummond និង អ្នកផ្សេងទៀត ឯកសារ D191/4 កថាខណ្ឌ ៣-៤។ Nicholson ឯកសារ D191/8 ទំព័រ ២-៦។

[104] Saul ឯកសារ D191/3 កថាខណ្ឌ ៤។ Drummond និង អ្នកផ្សេងទៀត ឯកសារ D191/4 កថាខណ្ឌ ៤ កថាខណ្ឌ ៨។ Trial ឯកសារ D191/5 កថាខណ្ឌ ២០។ Nicholson ឯកសារ D191/8 ទំព័រ ៥-៦។ Tsagourias ឯសារ D191/9 កថាខណ្ឌ ២៤។ Windridge ឯកសារ D191/10 កថាខណ្ឌ ៩។ QUB ឯកសារ D191/13 កថាខណ្ឌ ១១។

[105] *រឿងក្តី R* សំណុំរឿងលេខ StS 19/48 សេចក្តីសម្រេចក្នុងរឿងក្តីព្រហ្មទណ្ឌនៃតុលាការកំពូលនៅតំបន់ដែលកាន់កាប់ដោយអង់គ្លេស ភាគ ១ ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ១៩៤៨ ៤៦-៤៨។ តុលាការកំពូលចាត់ទុកបទល្មើសនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដូចគ្នានឹងបទល្មើសថ្នាក់ជាតិ ដោយតម្កល់ការផ្តន្ទាទោសមជ្ឈិមនេះ និង ពិន័យជាប្រាក់ចំនួន ៦០០០ RM ឬ ជាប់ពន្ធនាគារចំនួន ៦០ ថ្ងៃ បើទោះបីជាបានថ្លែងថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងច្បាប់លេខ ១០ នៃក្រុមប្រឹក្សាគ្រប់គ្រង ពាក់ព័ន្ធនឹងភាពអយុត្តិធម៌ធ្ងន់ធ្ងរក៏ដោយ។

[106] រឿងក្តី *H* សំណុំរឿងលេខ StS 309/49 សេចក្តីសម្រេចនៅក្នុងរឿងក្តីព្រហ្មទណ្ឌនៃតុលាការកំពូលនៅតំបន់ដែលកាន់កាប់ដោយអង់គ្លេស ភាគ ២ ចុះថ្ងៃទី ១៨ ខែតុលា ឆ្នាំ ១៩៤៩ ២៣៣ (ដែលបានកំណត់និយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិថាពាក់ព័ន្ធនឹងការរំលោភសិទ្ធិមនុស្សរបស់បុគ្គលម្នាក់ នៅក្នុងលក្ខណៈដែលធ្វើឲ្យប៉ះពាល់ដល់មូលដ្ឋាននៃសហគ្គិភាពមនុស្ស តាមរយៈអាកប្បកិរិយាល្មើសដោយដឹងខ្លួន និង មានចេតនា ទាក់ទងនឹងវិធានអំពីអំពើហិង្សា និង ផ្តាច់ការរបស់អ្នកសង្គមនិយមជាតិ) ២៣៨ កថាខណ្ឌ ២ និង ២៤៦។

[107] ផ្ទុយទៅនឹងអំណះអំណាងរបស់ Saul ឯកសារ D191/3 កថាខណ្ឌ ៤(ខ)។

ច្បាប់នេះ[108]។ រឿងក្តី *P និង អ្នកផ្សេងទៀត* បញ្ចេញប្រតិកម្មទៅនឹងរបបផ្តាច់ការ និង ហិង្សារបស់ Nazi[109]។ វាមានសំអាងហេតុគតិយុត្តិមិនគ្រប់គ្រាន់ដែលកំណត់ ឬ វិភាគលើធាតុផ្សំ *ទូទៅ* នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ រឿងក្តីទាំងនេះមិនបង្កើតបានជាទម្លាប់អនុវត្តន៍របស់រដ្ឋជាទូទៅ ឬ *ទស្សនៈច្បាប់* ដែលនិយមន័យតាមទំនៀមទម្លាប់នៃឧក្រិដ្ឋកម្ម ក្នុងឆ្នាំ ១៩៧៥-១៩៧៩ ឬ សព្វថ្ងៃ អនុញ្ញាតឲ្យទាហានត្រូវបានចាត់ទុកជាប្រជាជនស៊ីវិល តាមគោលបំណងនៃលក្ខខណ្ឌតម្រូវ *ទូទៅ* ឡើយ។

២៧. Saul អះអាងថា សេចក្តីសម្រេចអាឡឺម៉ង់ គឺទាក់ទងនឹងវិសាលភាពតាមទំនៀមទម្លាប់នៃពាក្យ "ប្រជាជនស៊ីវិលទាំងឡាយ" ពីព្រោះរដ្ឋជាក់ស្តែងមិនបានជំទាស់ទៅនឹងសេចក្តីសម្រេចទាំងនេះទេ[110]។ នាំឲ្យយល់ខុស។ សេចក្តីសម្រេចទាំងនេះមិនទាក់ទងនឹងនិយមន័យតាមទំនៀមទម្លាប់នៃពាក្យ "ប្រជាជនស៊ីវិល" នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ ប៉ុន្តែអាចតវ៉ាត្រឹមតែទៅលើបញ្ហាថាតើអ្នកណាអាចជាជនរងគ្រោះនៃឧក្រិដ្ឋកម្មនោះ។ មិនតម្រូវឲ្យរដ្ឋជំទាស់យុត្តិសាស្ត្រក្នុងស្រុកបរទេស ដែលពួកគេមិនយល់ស្រប ដើម្បីរារាំងយុត្តិសាស្ត្របែបនេះមិនឲ្យបង្ហាញឲ្យឃើញពីច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ[111]។ Saul ខកខានមិនបានផ្តល់មូលដ្ឋានដល់ការអះអាងរបស់គាត់ដែលថា ទម្លាប់អនុវត្តន៍រួមគ្នា តាមរយៈការប្រមូលចងក្រងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅពេលក្រោយ ក៏មិនបានបង្ហាញការជំទាស់ផងដែរ[112]។ ការប្រមូលចងក្រងនៅពេលក្រោយមកទៀត តម្រូវឲ្យការវាយប្រហារសំដៅលើប្រជាជន *ស៊ីវិល*[113]។

---

[108] រឿងក្តី *P និង អ្នកផ្សេងទៀត* សំណុំរឿងលេខ StS 111/48 សេចក្តីសម្រេចក្នុងរឿងក្តីព្រហ្មទណ្ឌរបស់តុលាការកំពូលនៅតំបន់ដែលកាន់កាប់ដោយប្រទេសអង់គ្លេស ភាគ ១ ចុះថ្ងៃទី ៧ ខែធ្នូ ឆ្នាំ ១៩៤៨ ២២៨។ ចៅក្រមបានពិភាក្សាអំពី *ធាតុផ្សំអត្តនោម័ត* (mens rea) ដែលតម្រូវឲ្យមានសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមយុត្តិសាស្ត្ររបស់ពួកគេ (*ដូចខាងលើ* ២២៤-២២៧)។

[109] *សូមមើល ដូចខាងលើ* ២២៤ ២២៨។

[110] Saul ឯកសារ D191/3 កថាខណ្ឌ ៦។

[111] ទោះជាយ៉ាងនេះក្តី ប្រសិនបើរដ្ឋបន្តជំទាស់យ៉ាងមុតមាំទៅនឹងការវិវឌ្ឍន៍នៃវិធានទំនៀមទម្លាប់ ក្រោយមករដ្ឋទាំងនោះនឹងមិនទទួលខុសត្រូវតាមច្បាប់នោះឡើយ នៅពេលដែលទំនៀមទម្លាប់នេះអាចអនុវត្តបាន។ រឿងក្តី *ដែននេសាទ (ចក្រភពអង់គ្លេស តទល់នឹង ន័រវេស)* របាយការណ៍ ICJ (ឆ្នាំ ១៩៥១) ទំព័រ ១៣៨-១៣៩។

[112] Saul ឯកសារ D191/3 កថាខណ្ឌ ៦។

[113] *សូមមើល* សារណា កថាខណ្ឌ ៤-៧។

២៨. *Barbie* និង *Touvier* ដែលដកស្រង់ដោយ *អ្នកដែលមិនមែនជាភាគី* មួយចំនួន[114] ក៏ចង្អុលបង្ហាញ *ត្រឹមតែ* ថា ទាហានអាចជា *ជនរងគ្រោះ* នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិប៉ុណ្ណោះ មិនមែនថាទាហានអាចជាប្រជាជនស៊ីវិលឡើយ។ ដូចដែលបានអះអាងដោយ Williams និង Grey[115] រឿងក្តីទាំងនេះមិនបានគាំទ្រទស្សនៈករណ៍ដែលថា ក្នុងករណីដែលទាហានជាគោលដៅរបស់រដ្ឋខ្លួនដោយសារមូលហេតុដែលមិនទាក់ទងនឹងជម្លោះប្រដាប់អាវុធ ជាពិសេស ដោយមូលហេតុរើសអើង ពួកគេគួរត្រូវបានចាត់ទុកជាជនស៊ីវិលក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ដូចដែល Nicholson បានបញ្ជាក់នាពេលថ្មីៗនេះ យុត្តិសាស្ត្រក្រោយឆ្នាំ ១៩៧៩ របស់សាលាក្តី *មិនអចិន្ត្រៃយ៍* ថ្លែងថាទាហាន រាប់បញ្ចូលទាំង *អ្នកដែលគ្មានលទ្ធភាពប្រយុទ្ធ* អាចជា *ជនរងគ្រោះ* (ជាចំណុចដែលមិនជំទាស់ដោយមេធាវីការពារក្តី) ប៉ុន្តែ *មិនអាច* ជាប្រជាជនស៊ីវិលឡើយ[116]។

២៩. បើទោះជារឿងក្តីអាឡឺម៉ង់ និង បារាំង ចង្អុលបង្ហាញអំពីនិយមន័យតាមទំនៀមទម្លាប់នៃពាក្យ "ប្រជាជនស៊ីវិល" ក៏ដោយ ក៏មិនអាចមើលឃើញរឿងក្តីទាំងនេះជាមុន ឬ អាចដឹងបានឡើយ ក្នុងឆ្នាំ ១៩៧៥-១៩៧៩ សម្រាប់អ្នកនៅក្រៅប្រទេសអាឡឺម៉ង់ ឬ បារាំង។ សូម្បីតែសព្វថ្ងៃនេះ រឿងក្តីទាំងនេះមិនត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ ឬ មានជាភាសាផ្សេងទៀតក្រៅពីភាសាអាឡឺម៉ង់ ឬ បារាំងផង[117]។

---

[114] Drummond និង អ្នកផ្សេងទៀត ឯកសារ D191/4 កថាខណ្ឌ ៩។ Trial ឯកសារ D191/5 ជើងទំព័រ ៣៥។ Robinson និង អ្នកផ្សេងទៀត ឯកសារ D191/6 កថាខណ្ឌ ១៣។ Windridge ឯកសារ D191/10 កថាខណ្ឌ ៩។ Williams & Grey ឯកសារ D191/11 ជើងទំព័រ ១៧។ QUB ឯកសារ D191/13 កថាខណ្ឌ ៥។

[115] Williams & Grey ឯកសារ D191/11 កថាខណ្ឌ ១៦។

[116] Nicholson បានធ្វើសេចក្តីថ្លែងការណ៍នេះ ក្នុងការបង្ហោះក្នុងប្លុកនៅថ្ងៃទី ៤ ខែកក្កដា ឆ្នាំ ២០១៦ សម្រាប់ *ទស្សនៈច្បាប់*។ *សូមមើលផងដែរ* ជើងទំព័រ ៧៥ *ខាងលើ*។

[117] មេធាវីការពារក្តីមិនអាចស្វែងរកការបកប្រែជាភាសាអង់គ្លេសនៃសេចក្តីសម្រេចជាភាសាអាឡឺម៉ង់នេះបានឡើយ គឺមានត្រឹមតែសេចក្តីសង្ខេបជាភាសាអង់គ្លេសប៉ុណ្ណោះ។ ការិយាល័យសហចៅក្រមស៊ើបអង្កេតបានបដិសេធសំណើសុំការបកប្រែសេចក្តីសម្រេចទាំងនេះជាភាសាអង់គ្លេស។ *សូមមើល* ដីកាសម្រេចលើសំណើសុំទទួលបានការបកប្រែជាភាសាអង់គ្លេសនៃសេចក្តីសម្រេចចំនួនបីជាភាសាអាឡឺម៉ង់ និង សេចក្តីសម្រេចមួយជាភាសាហូឡង់ ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D191/16/1។ អង្គភាពបកប្រែភាសានៃ អ.វ.ត.ក. បានបដិសេធមិនបកប្រែសេចក្តីសម្រេចទាំងនេះ បើគ្មានដីកាបង្គាប់ពីតុលាការ។ មេធាវីការពារក្តីត្រូវស្វែងរកសេវាពីអ្នកបកប្រែខាងក្រៅ។ ឯកសារបកប្រែមាននៅក្នុងឧបសម្ព័ន្ធ ខ ដែលធ្វើឱ្យរឿងក្តីទាំងនេះអាចអានបានជាភាសាអង់គ្លេស ប្រហែលជាជាលើកដំបូង។

### ឆ. ថាតើការសម្លាប់ទាហានរបស់រដ្ឋអាចជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ឬយ៉ាងណា គឺមិនជាប់ទាក់ទង

៣០. Baltimore អះអាងថា ការណ៍ដែលរដ្ឋដាក់ទាហានរបស់ខ្លួនជាគោលដៅដោយប្រព័ន្ធ អាចជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍[118]។ មិនពាក់ព័ន្ធ។ ថាតើទង្វើមួយចំនួនជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ឬយ៉ាងណា មិនមែនជាកត្តាកំណត់ថាតើទង្វើនោះជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឬយ៉ាងណាឡើយ។ ឧក្រិដ្ឋកម្មនីមួយៗមានធាតុផ្សំខុសគ្នា[119]។ អនុសញ្ញាស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មិនតម្រូវឲ្យអំពើប្រល័យពូជសាសន៍ ត្រូវតែប្រព្រឹត្តិជាផ្នែកនៃការវាយប្រហារប្រឆាំងនឹងប្រជាជនស៊ីវិលឡើយ។ Baltimore បកស្រាយរឿងក្តី *Krstić* មិនត្រឹមត្រូវ។ Baltimore អះអាងថា មិនចាំបាច់ដាក់កម្រិតឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ឲ្យនៅត្រឹមតែក្រុមជាតិពិន្ទុ ឬ ក្រុមពូជសាសន៍នោះឡើយ ពីព្រោះអង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា Krstić បានប្រព្រឹត្តិឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ទោះបីជាគាត់មានទទឹ្ធករណ៍ថា គាត់បានដាក់គោលដៅតែលើមនុស្សប្រុសដល់អាយុចូលធ្វើយោធា ដើម្បីកាត់បន្ថយសត្រូវជាជនជាតិបូស្នៀរអ៊ីស្លាមឲ្យនៅតិចបំផុតក៏ដោយ[120]។ អង្គជំនុំជម្រះពុំបានពង្រីកវិសាលភាពនិយមន័យនៃអំពើប្រល័យពូជសាសន៍ឡើយ[121]។ អង្គជំនុំជម្រះបានកំណត់ថា តើការសម្លាប់ផ្នែកនៃក្រុមមួយអាចជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ឬយ៉ាងណា។ Krstić មានចេតនាបំផ្លិចបំផ្លាញមួយផ្នែកធំនៃក្រុមបូស្នៀរអ៊ីស្លាម។ ហេតុផលរបស់គាត់ក្នុងការធ្វើដូច្នេះ គឺមិនពាក់ព័ន្ធ[122]។

## II. សន្និដ្ឋាន

៣១. ក្នុងឆ្នាំ ១៩៧៥-១៩៧៩ ធាតុផ្សំ *ទូទៅ* នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បានតម្រូវឲ្យមានការវាយប្រហារសំដៅលើ *ប្រជាជនស៊ីវិល*។ លក្ខខណ្ឌតម្រូវនេះមិនបណ្តាលឲ្យមានលទ្ធផលដែលមិនអាចទទួលយកបានឡើយ។ ពុំអាចមិនមានលក្ខខណ្ឌតម្រូវនេះ ដោយសារតែលក្ខខណ្ឌនេះមិនបង្គ

[118] Baltimore ឯកសារ D191/12 កថាខណ្ឌ ១៧-២០។

[119] *សូមមើល* រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Nahimana និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ICTR-99-52-A សាលក្រម ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០០៧ កថាខណ្ឌ ១០២៩។

[120] Baltimore ឯកសារ D191/12 កថាខណ្ឌ ១៩។

[121] *សូមមើល* រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Krstić* សំណុំរឿងលេខ IT-98-33-T សាលក្រម ចុះថ្ងៃទី ២ ខែ សីហា ឆ្នាំ ២០០១ កថាខណ្ឌ ៥៥៤។

[122] *ដូចខាងលើ* កថាខណ្ឌ ៥៤៩ កថាខណ្ឌ ៥៥៨-៥៦៨ កថាខណ្ឌ ៥៩១ កថាខណ្ឌ ៥៩៤។

ឲ្យមានភាពងាយស្រួល ឬ រំខាននោះឡើយ។ វាមិនអាចត្រូវបានពង្រីកវិសាលភាព ដើម្បីបញ្ចូលទាហាន ដើម្បីសម្រាលការព្រួយបារម្ភខាងគោលនយោបាយ ឬ សីលធម៌នោះទេ។ ការវាយប្រហារសំដៅលើប្រជាជនមិនមែនស៊ីវិល មិនមែនជាផ្នែកមួយនៃធាតុផ្សំ *ទូទៅ* ជាធរមាននៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ។ អ.វ.ត.ក. ត្រូវតែអនុវត្តនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានមានអត្ថិភាពក្នុងឆ្នាំ ១៩៧៥-១៩៧៩[123] និង មានចែងក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.[124] ឲ្យតែអាចមើលឃើញជាមុន និង អាចដឹងបាន[125]។ តាមគោលការណ៍នីត្យានុកូលភាព ចៅក្រមមិនអាចបង្កើតច្បាប់ថ្មី ឬ បកស្រាយច្បាប់ដែលមានស្រាប់ឲ្យ "ហួសពីព្រំដែនសមស្របនៃការបញ្ជាក់បំភ្លឺដែលអាចទទួលយកបានឡើយ"[126]។ ប្រសិនបើសហចៅក្រមស៊ើបអង្កេតកែប្រែ ឬ ពង្រីកវិសាលភាពនៃនិយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដើម្បីបញ្ចូលទាហានក្នុងនាមជា "ប្រជាជនស៊ីវិល" សហចៅក្រមស៊ើបអង្កេតនឹងរំលោភគោលការណ៍ដែលត្រូវបានទទួលស្គាល់ជាយូរនេះ និង ករណីយកិច្ចតុលាការរបស់ពួកគេ។

សូមលោកចៅក្រមមេត្តាទទួលយកចម្លើយនេះដោយក្តីគោរពអំពីយើងខ្ញុំ។

---

[123] ដូចដែលបង្ហាញដោយទម្លាប់អនុវត្តន៍របស់រដ្ឋ និង*ទស្សនៈច្បាប់* ដែលមានក្នុងករណីដែលមានការប្រើប្រាស់ទូលំទូលាយ និងដូចគ្នាទាំងស្រុងពីសំណាក់រដ្ឋនូវវិធានណាមួយ ហើយរដ្ឋចាត់ទុកទម្លាប់អនុវត្តន៍នេះជាកាតព្វកិច្ចតាមច្បាប់។ រឿងក្តី *ឧបទ្វីបសមុទ្រខាងជើង* របាយការណ៍ ICJ (ឆ្នាំ ១៩៦៩) កថាខណ្ឌ ៧៤។ រឿងក្តី *នីការ៉ាហ្គា តទល់នឹង ស.រ.អ.* (អង្គសេចក្តី) របាយការណ៍ ICJ (ឆ្នាំ ១៩៨៦) កថាខណ្ឌ ២០៧។

[124] "ខណៈដែលពាក្យពេចន៍ជាក់លាក់សំខាន់ ពុំមែនមិនត្រូវបានឮ វាប្រាកដជាករណីលើកលែង។ តុលាការជាទូទៅនឹងមិនប្រើប្រវត្តិនីតិបញ្ញត្តិ ដើម្បីលុបលើពាក្យពេចន៍ច្បាប់ដែលហាក់ដូចជាសាមញ្ញជាក់ស្តែង យ៉ាងហោចណាស់នៅពេលដែលអត្ថន័យសាមញ្ញនោះ គឺសមហេតុផល។ វិធីសាស្ត្រនេះស៊ីសង្វាក់នឹងចេតនារបស់អង្គនីតិបញ្ញត្តិ។ ពីព្រោះពាក្យពេចន៍ច្បាស់លាស់ ជាភស្តុតាងរឹងម៉ាំនៃចេតនា ជាទូទៅ វាគួរមានសារៈសំខាន់ជាងភស្តុតាងដែលមិនសូវឲ្យជឿជាក់បាន ដូចជាប្រវត្តិនីតិបញ្ញត្តិ។ ក្នុងរយៈពេលវែង ប្រសិនបើតុលាការអនុវត្តញឹកញាប់នូវទម្លាប់ជំទាស់ពាក្យពេចន៍ច្បាប់ដែលច្បាស់លាស់ សមាជនឹងបាត់បង់មធ្យោបាយប្រពៃបំផុតសម្រាប់ប្រាស្រ័យទាក់ទងអំពីចេតនារបស់ខ្លួន។ ដូចនេះ វិធាន "ពាក្យពេចន៍សាមញ្ញ" ដែលសន្មត ដែលដាក់កម្រិតលើការប្រើប្រាស់ប្រវត្តិនីតិបញ្ញត្តិ នៅពេលពាក្យពេចន៍ច្បាប់ច្បាស់លាស់ ពិតជាអាចជួយអនុវត្តចេតនាអង្គនីតិបញ្ញត្តិបាន។" DANIEL A. FARBER & PHILIP P. FRICKEY ច្បាប់ និង ជម្រើសជាសាធារណៈ៖ សេចក្តីណែនាំស៊ីជម្រៅ (LAW AND PUBLIC CHOICE: A CRITICAL INTRODUCTION) ៩៤ (សារព័ត៌មានសកលវិទ្យាល័យ Chicago ឆ្នាំ១៩៩១)។

[125] កថាខណ្ឌ ៩៦ នៃសាលដីកា *ឌុច*។ សូមមើលផងដែរ កថាខណ្ឌ ៨៩-៩១ សម្រាប់ការពិភាក្សាអំពីគោលការណ៍នីត្យានុកូលភាព។

[126] *ដូចខាងលើ* កថាខណ្ឌ ៩៥ ដោយដកស្រង់រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* *Milutinović* *និង អ្នកផ្សេងទៀត* សំណុំរឿង IT-99-37-AR72 សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍លើញត្តិរបស់ Dragoljub Ojdanić ដែលជំទាស់យុត្តាធិការ សហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ២១ ខែឧសភា ឆ្នាំ ២០០៣ កថាខណ្ឌ ៣៨។

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **១១** ខែកក្កដា ឆ្នាំ **២០១៦**

សហមេធាវីការពារក្តីលោក មាស មុត

**អាង ឧត្តម** Michael G. KARNAVAS